August-2008.qxd 7/29/2008 10:16 AM Page 1

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១ ថ្ងៃទី០១-៣១ ខែសីហា ឆ្នាំ២០០៨ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ១២

## មាតិកា



ទិវាជួបជុំយុវជនពិភពលោក ប្រចាំឆ្នាំ២០០៨ ទំព័រ ៧



ការងារស្ម័គ្រចិត្តនៃយុវជនខ្មែរនៅឯក្រៅប្រទេស ទំព័រ ៨



កំពូលយុទ្ធគុណខ្មែរ ក្បាច់ខម ទំព័រ ១៤

# អំពើរំលោភសេពសន្ថវៈកើនឡើង និងមូលហេតុនៃបញ្ហា

ទំព័រទី១០...




SIPAR
សៀវភៅធ្វើអោយអ្នកចេះ
មានលក់នៅតាមបណ្ណាគារ
និងតូបលក់សៀវភៅនានា
023 216 001
siparedition@online.com.kh



កម្មវិធីវិទ្យុ
អេម៉ានូអែល សំឡេងពីព្រះសហគមន៍កាតូលិក !
ភ្នំពេញ : FM 99.5 Mhz ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១០:០០-១១:០០ ថ្ងៃ សៅរ៍/អាទិត្យ
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:០០-១៣:០០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 100.5 Mhz ម៉ោង៦:០០-៧:០០ យប់ថ្ងៃសៅរ៍
កំពត : FM 92.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

# រូបថតសម្រាប់លេខនេះ



ប្រជាពលរដ្ឋរាជធានីភ្នំពេញ ជួបជុំគ្នាកាលពីថ្ងៃទី១៤ កក្កដា កន្លងទៅនៅពហុកីឡាដ្ឋានអូឡាំពិកដើម្បីអបអរការចុះបញ្ជីប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោក និងក៏ជាការស្វាគមន៍ឯកឧត្តមសុខ អាន រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ដែលវិលមកពីការបំពេញបេសកកម្មនៃការចុះបញ្ជីនេះនៅទីក្រុងកេបិច ប្រទេសកាណាដា **(ឆ្វេង)**

ប្រជាពលរដ្ឋនៅទូទាំងរាជធានីភ្នំពេញរាប់ម៉ឺននាក់បានសម្តែងនូវសេចក្តីរំភើបរីករាយជាខ្លាំងដែលប្រាសាទព្រះវិហាររបស់ខ្មែរត្រូវបានចុះបញ្ជីជាបេតិកភណ្ឌពិភពលោក ដែលនេះជាមោទភាពដ៏ធំធេងសម្រាប់ជាតិខ្មែរយើង **(ក្រោម)**

ការរីកចម្រើនខាងវិស័យសេដ្ឋកិច្ចជាតិនាប៉ុន្មានឆ្នាំចុងក្រោយនេះ បានជំរុញឱ្យការដឹកជញ្ជូន និងការធ្វើដំណើរបំផ្លាស់ទីរបស់ប្រជាជនមានសភាពមមាញឹកជាខ្លាំង។ ដើម្បីចំណាយថោក បងប្អូនយើងខ្លះហ៊ានធ្វើដំណើរលើដំបូលរថយន្ត ដែលពួកគាត់មិនដឹងថា ទង្វើបែបនេះមានការប្រថុយនឹងគ្រោះថ្នាក់ខ្លាំងណាស់សម្រាប់ជីវិត **(ក្រោម)**





សមាគមកុមារកំព្រាមួយ បានដឹកនាំឱ្យកុមារៗឱ្យរាំក្បាច់ហ៊ិបហបដើម្បីប្រមូលលុយយកឧបត្ថម្ភការសិក្សារបស់កុមារកំព្រាទាំងនោះ។ តើនេះអាចចាត់ទុកជាសកម្មភាពនៃពលកម្មកុមារដែរឬទេ? **(ក្រោម)**



Photos : L. Sovanna

ក្បាច់ហ៊ិបហបដែលមានប្រភពនៅសហរដ្ឋអាមេរិកបានរីកសាយភាយនៅទូទាំងពិភពលោក។ ក្នុងនោះសង្គមខ្មែរក៏បានទទួលយកចង្វាក់ដ៏ពេញនិយមដែរ ជាពិសេសក្នុងចំណោមយុវវ័យក្មេង។ យុវជនវ័យក្មេងម្នាក់នេះកំពុងសម្តែងចាក់ក្បាច់ហ៊ិបហប។ **(ឆ្វេង)**





# វិចារណកថា

## យើងរួមគ្នា ការពារនារី និងកុមាររបស់យើង



Photo : P. Samphy

លោកបូជាចារ្យ អូមែរ ហ្ស៊ីរ៉ាល់ដូ ប្រធានមណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក (CSC)

មួយរយៈកាលចុងក្រោយនេះ ប្រទេសកម្ពុជាបានសម្តែងការព្រួយបារម្ភកាន់តែខ្លាំងឡើងៗ ពីបញ្ហារំលោភសេពសន្ថវៈមកលើក្មេងៗនៅក្នុងគ្រួសារ និងក្នុងសង្គម ។

សម្រាប់ព្រះសហគមន៍កាតូលិកយើង ព្រះជាម្ចាស់បានបង្កើតមនុស្សប្រុសស្រី និងបានពិចារណាអំពីសេចក្តីស្រលាញ់រវាងប្តីប្រពន្ធថាជាកិច្ចការសំខាន់បំផុតសម្រាប់បង្កើតគ្រួសារ ។ តាមហេតុផលនេះ ព្រះសហគមន៍កាតូលិកក៏ពិចារណាអំពីការចងសម្ពន្ធរវាងបុរស-ស្ត្រី ដែលនេះជាសុភមង្គលមួយបង្កើតឡើងដោយព្រះជាម្ចាស់ ។ តាមប្រពៃណីកាតូលិក សម្ពន្ធភាពរវាងប្តីប្រពន្ធបាននាំឱ្យពួកគេចេះរួបរួមគ្នា ជាមួយនិងព្រះជាម្ចាស់ ដោយសារតែវាមិនមែនតែការចងសម្ពន្ធរាងកាយប៉ុណ្ណោះទេ ប៉ុន្តែជាសម្ពន្ធខាងវិញ្ញាណរបស់ព្រះជាម្ចាស់ផងដែរ ។

នៅក្នុងបរិបទនេះ យើងពិតជាមានការឈឺចាប់ជាខ្លាំងចំពោះទម្រង់នៃអំពើហិង្សា និងការរំលោភសេពសន្ថវៈមកលើកុមារដែលប្រព្រឹត្ត ដោយសមាជិកគ្រួសារ និងសាច់ញាតិរបស់ពួកគេ ។ ក្នុងគម្ពីរគ្រីស្តសាសនា សន្តប៉ូលបានសរសេរសំបុត្រមួយច្បាប់ជូនប្រជាជនក្រុងរ៉ូម នៅក្នុងជំពូកទី១៣ ដែលនិយាយពីទំនាក់ទំនងផ្លូវភេទដែលគ្មានសីលធម៌នោះថា : ចូរ ! រស់នៅឱ្យបានត្រឹមត្រូវជារៀងរាល់ថ្ងៃ មិនស៊ីផឹកស្រវឹង មិនប្រព្រឹត្តកាមតណ្ហានៅក្រៅតម្រា មិនប្រាសចាកសីលធម៌ មិនឈ្លោះប្រកែក និងមិនច្រណែនឈ្នានីសគ្នា(រ៉ូម ១៣:១៣-១៤) ។

តើយើងដោះស្រាយបញ្ហា ដែលកំពុងប្រឈម នៅក្នុងគ្រួសារដោយរបៀបណា? យើងគឺត្រូវបង្កើតក្រមសីលធម៌ និងច្បាប់ប្រឆាំងឧក្រិដ្ឋកម្មផ្លូវភេទកុមារ ហើយត្រូវធ្វើការផ្សព្វផ្សាយ និងអនុវត្តឱ្យបានទូលំទូលាយ ។ ដោយហេតុថា នៅពេលដែលក្រមសីលធម៌មិនមានវត្តមាននៅក្នុងគ្រួសារ និងសង្គម តណ្ហានឹងផ្លាស់ប្តូរជីវិតមនុស្ស ពេលនោះភាពច្របូកច្របល់ និងអំពីចាប់រំលោភផ្សេងៗ នឹងកើតមានឡើង ។ ចូរ ! យើងទាំងអស់គ្នារួបរួមគ្នាជាធ្លុងមួយ ក្នុងការបំពេញកិច្ចការទាំងនេះ ដើម្បីជួយសង្គ្រោះកុមារី និងសុភាពនារីរបស់យើង ។


ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ

Tel/Fax : (855) 23 224 120;

E-mail : csccambodia@gmail.com

Website : www.catholiccambodia.org

ក្រុមប្រឹក្សាភិបាល : លោកអភិបាល អេមីល ដេតម្ប និងលោកអូមែរ ហ្ស៊ីរ៉ាល់ដូ ។

ចាងហ្វាងការផ្សាយ : លោកលី សុវណ្ណា ។

Licence ១៨៣ ពម.ប្រក./២៥-មិថុនា-២០០៧



**មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក** មានចេញលក់នូវស៊ីឌីចម្រៀងវ៉ុលទី៩ ថ្មី ដែលជាចម្រៀងពណ៌នាអំពីតង្វាយដែលថ្វាយទៅព្រះជាម្ចាស់។ តម្លៃលក់ក្នុងមួយស៊ីឌី ៨ ០០០រៀល តែប៉ុណ្ណោះ។ ហេតុដូចនេះ ប្រសិនប្រិយមិត្តមានចំណាប់អារម្មណ៍ចង់ជាវនោះ សូមទំនាក់ទំនងទូរស័ព្ទ : ០១២ ២៤៤ ៧៧៨។

## មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក

**សេវាកម្មជាទីគាប់ចិត្ត !** ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកមានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និងMP3 និងទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទផងដែរ។ គ្រប់សេវាកម្មទាំងអស់គិតក្នុងតម្លៃសមរម្យ។ សូមប្រិយមិត្តទាក់ទងទូរស័ព្ទ : ០១២ ៣៧៧ ៩៦០។


### សារសម្រាប់មិត្តអ្នកអាន!

បើប្រិយមិត្តចង់មានមតិយោបល់ទៅលើអត្ថបទ មានចម្ងល់ ឬចង់ជូននូវមតិរិះគន់ស្ថាបនា សូមទាក់ទងមកកាន់អាសយដ្ឋានរបស់យើងខ្ញុំ។ យើងខ្ញុំនឹងផ្តល់នូវចម្លើយដោយក្តីរីករាយ។



### ចម្លើយសម្រាប់ទំព័រទី១៦




**សៀវភៅចេញថ្មី !** *"ចាកផុតពីឋាននរក ៤ឆ្នាំក្នុងរបបខ្មែរក្រហម"*




និទានពីជីវិតពិតក្នុងរបបខ្មែរក្រហមរបស់អ្នកស្រីក្លែរ លី (Claire LY) ជាអ្នកនិពន្ធ។ សៀវភៅនេះណែនាំបងប្អូនឱ្យរិះគិតយ៉ាងជ្រៅពីជីវិតខាងវិញ្ញាណក្នុងសាសនាទាំងពីរ : ពុទ្ធសាសនា និងគ្រីស្តសាសនា។ សៀវភៅនេះមាននៅមណ្ឌលវប្បធម៌កាតូលិក ផ្ទះលេខ ៥៧ ផ្លូវ ១០១ សង្កាត់បឹងត្របែក-ភ្នំពេញ។ ទូរស័ព្ទ : ០២៣២១១២៥៣។

August-2008.qxd 7/29/2008 10:16 AM Page 4

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

### ថ្ងៃអាទិត្យ ទី១៨ នៃរដូវធម្មតា (ថ្ងៃទី៣ សីហា ឆ្នាំ២០០៨)

(ម៉ាថាយ ១៤,១៣-២១) ព្រះបន្ទូលដំណឹងល្អថ្ងៃនេះនិយាយពីព្រះយេស៊ូចង់នៅឆ្ងាយពីបណ្ដាជនបន្ទាប់ពីសន្ដយ៉ូហាន បាទីស្ដត្រូវបានគេប្រហារជីវិត ។ ពេលព្រះយេស៊ូ និងសាវ័ក មកដល់ត្រើយម្ខាង មានមហាជនដ៏ច្រើនកំពុងរង់ចាំ ។ ពួកសាវ័កមានការហេវហត់ជាខ្លាំង រួចនិយាយថា: "ទីនេះ ស្ងាត់ណាស់ ! ហើយក៏ជិតយប់ផង សូមប្រាប់បណ្ដាជនទាំងនេះ ត្រលប់ទៅវិញ រកទិញម្ហូបអាហារនៅតាមភូមិ" ។ ព្រះយេស៊ូបានមានព្រះបន្ទូលឱ្យសាវ័កយកម្ហូបអាហារឱ្យពួកគេបរិភោគទៅ ។ ព្រះយេស៊ូចង់បង្ហាញពីជំនឿជាក់លើខ្លួនឯងដោយជំរុញពួកគេឱ្យចែករំលែកអាហារដែលពួកគេមានបន្ដិចបន្តួចនោះ ។ លោកម៉ាថាយ និយាយថា: "បណ្ដាជនបរិភោគអាហារឆ្អែតគ្រប់ៗគ្នា រួចពួកសាវ័កប្រមូលនំប៉័ងនៅសល់ដាក់បានពេញ ១២ល្អី ។

### ថ្ងៃអាទិត្យ ទី១៩ នៃរដូវធម្មតា (ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៨)

(ម៉ាថាយ ១៤,២២-៣៣) នៅពេលបណ្ដាជនរាប់ពាន់នាក់ហូបអាហារឆ្អែតគ្រប់ៗគ្នា ព្រះយេស៊ូក៏បញ្ជូនពួកសាវ័កឱ្យឆ្លងទៅត្រើយម្ខាង និងប្រាប់មហាជនឱ្យវិលត្រលប់ទៅវិញ ។ ក្រោយមកព្រះយេស៊ូ "ឡើងទៅលើភ្នំដាច់ដោយឡែកពីគេដើម្បីអធិដ្ឋាន" ។ ពួកសាវ័កក៏បានជួបរលកបោកបក់ធំៗ និងខ្យល់គួចយ៉ាងខ្លាំងនៅលើទឹក ។ ពេលនោះពួកសាវ័កមើលឃើញមនុស្សម្នាក់ថា ជាខ្មោចដើរនៅលើសមុទ្រ ។ ពួកសាវ័កភ័យជាខ្លាំង នៅមុនពេលបានឮសំឡេងព្រះយេស៊ូថា: "ចូរតាំងចិត្តក្លាហានឡើង ! ខ្ញុំទេតើ ! កុំខ្លាចអី !" ពេលនោះលោកសិលាហ៊ានដើរនៅលើទឹក ។ ព្រះយេស៊ូក៏បានមានព្រះបន្ទូលថា: "អញ្ជើញមក !" ។ ពេលលោកដើរបានប៉ុន្មានជំហាន ក៏លិចចូលទៅក្នុងទឹក ហើយស្រែកថា លោកម្ចាស់អើយ ! សូមជួយខ្ញុំផង ! ។ ព្រះយេស៊ូលូកព្រះហស្ដទាញគាត់ឡើងភ្លាមទាំងមានព្រះបន្ទូលថា: "មនុស្សមានជំនឿតិចអើយ ! ហេតុដូចម្ដេចអ្នកមិនទុកចិត្តដូច្នេះ ?"

### ថ្ងៃអាទិត្យ ទី២០ នៃរដូវធម្មតា (ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៨)

(ម៉ាថាយ១៥,២១-២៨) "ឱ ! ព្រះអម្ចាស់ ជាព្រះរាជវង្សរបស់ព្រះបាទដាវីឌអើយ ! សូមអាណិតមេត្តាខ្ញុំម្ចាស់ផង កូនស្រីខ្ញុំម្ចាស់ត្រូវខ្មោចចូលបណ្ដាឱ្យវេទនាខ្លាំងណាស់" គឺស្ដ្រីសាសន៍កាណានម្នាក់ពោលទៅព្រះយេស៊ូ ។ ពួកសាវ័កព្រះយេស៊ូនាំគ្នាមកជិតព្រះអង្គ ហើយទូលថា: "សូមព្រះគ្រូប្រោសប្រណី ដល់នាងផងព្រោះនាងចេះតែស្រែកអង្វរពីក្រោយយើង" ។ ក្រោយមកព្រះយេស៊ូមានព្រះបន្ទូលថា: "ព្រះជាម្ចាស់បានចាត់ឱ្យខ្ញុំមករកតែមនុស្សណា ដែលវង្វេងនៅក្នុងចំណោមជនជាតិអ៊ីស្រាអែលប៉ុណ្ណោះ" ។ តែជំនឿដ៏មុតមាំ និងសេចក្ដីតស៊ូរបស់ស្ដ្រីសាសន៍កាណាន បានធ្វើឱ្យព្រះយេស៊ូផ្លាស់ប្ដូរគំនិត ទោះបីស្ដ្រីរូបនេះមានវប្បធម៌ ភាសា ឬក៏ជំនឿសាសនាផ្សេងគ្នាក៏ដោយ ។

### ថ្ងៃអាទិត្យ ទី២១ នៃរដូវធម្មតា (ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៨)

(ម៉ាថាយ ១៦,១៣-២០) ព្រះបន្ទូលដំណឹងល្អនៅថ្ងៃនេះនិយាយពីការប្រកាសជំនឿរបស់លោកសិលា ។ "លោកគឺជាព្រះគ្រីស្ដជាព្រះបុត្រារបស់ព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ" លោកសិលាគឺទូលព្រះអង្គដូច្នេះ ។ព្រះយេស៊ូបានឆ្លើយតបលោកសិលាថា: "ខ្ញុំសូមប្រាប់អ្នកថា អ្នកឈ្មោះសិលា ហើយនៅលើផ្ទាំងសិលានេះ ខ្ញុំនឹងសង់ព្រះសហគមន៍របស់ខ្ញុំ" ។ លោកសិលាជាផ្ទាំងថ្មដ៏រឹងមាំមួយ ហើយក៏ជាមូលដ្ឋានគ្រឹះរបស់ព្រះសហគមន៍ដ៏រឹងមាំដែលអាចធ្វើជាសាក្សីផ្ទាល់របស់ព្រះយេស៊ូគ្រីស្ដ ។ ព្រះសហគមន៍មិនមែនជាព្រះរាជ្យរបស់ព្រះជាម្ចាស់ទេ ប៉ុន្ដែព្រះយេស៊ូបានប្រទានឱ្យលោកសិលាទទួលនូវសោ ដែលគឺជានិមិត្តរូបសម្រាប់នាំឱ្យបណ្ដាជនទៅកាន់ព្រះរាជ្យព្រះជាម្ចាស់បាន ។

### ថ្ងៃអាទិត្យ ទី២២ នៃរដូវធម្មតា (ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៨)

(ម៉ាថាយ១៦,២១-២៧) ព្រះបន្ទូលដំណឹងល្អថ្ងៃនេះ ព្រះយេស៊ូចង់ឱ្យក្រុមសាវ័កដឹងថា: "ព្រះអង្គត្រូវយាងទៅកាន់ក្រុងយេរូសាឡឹម ។ ពួកនាយក បូជាចារ្យ ពួកព្រឹទ្ធាចារ្យ និងពួកបណ្ឌិតខាងវិន័យនឹងនាំគ្នាធ្វើបាបព្រះអង្គឱ្យរងទុក្ខលំបាកជាខ្លាំង" ។ ពេលនោះព្រះយេស៊ូក៏បានឆ្លើយតបថា: "នែ ! ពួកមារសាតាំងអើយ ! ថយទៅខាងក្រោយខ្ញុំ ដ្បិតអ្នកកំពុងរារាំងផ្លូវខ្ញុំ ។ គំនិតអ្នកមិនមែនជាគំនិតព្រះជាម្ចាស់ ប៉ុន្ដែជាគំនិតរបស់មនុស្សលោកសុទ្ធសាធ" ។ តាំងពីពេលនោះមកលោកសិលាទទួលស្គាល់ព្រះអង្គជាព្រះគ្រីស្ដ ។ គ្រីស្ដបរិស័ទមានជំនឿលើព្រះមេស្ស៊ី ដែលជាព្រះគ្រីស្ដដែលគ្មានអំណាចតាមលោកីយ៍នេះ តែមានសេចក្ដីស្រលាញ់ ជាអ្នកបម្រើប្រជាជន និងជាអ្នកផ្ដល់ជីវិតដើម្បីសង្គ្រោះមនុស្សលោកទាំងមូល ។

*(អ្នកនាំសារ ខែសីហា ២០០៨ - អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ / លោកឪពុក អូម៉ែរ ហ្សីរ៉ាល់ដូ)*

## សម្រាប់កុមារ



Photo: DR

អ្នកនាំសារ សូមបង្ហាញប្អូនៗ អំពីរឿងរ៉ាវព្រះយេស៊ូត្រាស់ហៅលោកសាខេ។ តើប្អូនៗធ្លាប់ឮរឿងអំពីព្រះយេស៊ូត្រាស់ហៅលោកសាខេនេះដែរឬទេ ? តើលោកសាខេជានរណា ?

តាមគម្ពីរបានអធិប្បាយឱ្យឃើញថា លោកសាខេជាមេអ្នកទារពន្ធនៅក្នុងក្រុងយេរីខូ។ ជាធម្មតា អ្នកទារពន្ធនៅក្នុងសម័យព្រះយេស៊ូត្រូវបានគេចាត់ទុកថា ជាមនុស្សបាប ពីព្រោះអ្នកទាំងអស់នោះ ទារពន្ធពីប្រជាជនលើសកម្រិតដែលរដ្ឋបានកំណត់។ ហើយពួកគេធ្វើបាបអ្នកក្រីក្រ ដែលគ្មានលុយបង់ យ៉ាងធ្ងន់ធ្ងរ។

**តើព្រះយេស៊ូត្រាស់ហៅលោកសាខេបានយ៉ាងដូចម្ដេច ?**

នៅពេលព្រះយេស៊ូយាងមកដល់ទីក្រុងយេរីខូ។ លោកសាខេចង់ឃើញព្រះយេស៊ូណាស់ តើព្រះអង្គមានភិនភាគយ៉ាងណា ? ប៉ុន្ដែលោកមើលមិនឃើញទេ ដោយសារមានមនុស្សច្រើនពេកចោមរោមព្រះអង្គ ហើយដោយសារលោកមានមាឌតូច និងកម្ពស់ទាបផង។ តើលោកត្រូវធ្វើដូចម្ដេច ? លោករត់ទៅខាងមុខ ហើយឡើងដើមឈើមួយដើមនៅតាមផ្លូវដែលព្រះអង្គត្រូវយាងកាត់ដើម្បីមើលព្រះយេស៊ូ។ ពេលព្រះយេស៊ូយាងទៅដល់កន្លែងនោះ ព្រះអង្គងើបព្រះភ័ក្ត្រឡើងមើលលោកសាខេ ហើយហៅលោកចុះមកដោយមានបន្ទូលថា: "លោកសាខេអើយ សូមអញ្ជើញចុះមកជាប្រញាប់ ដ្បិតថ្ងៃនេះខ្ញុំត្រូវការទៅស្នាក់នៅផ្ទះលោក"។ ពេលនោះលោកមានចិត្តត្រេកអរខ្លាំងណាស់ ហើយប្រញាប់ប្រញាល់ទទួលព្រះយេស៊ូទៅកាន់ផ្ទះរបស់លោក។ ពេលព្រះយេស៊ូកំពុងបរិភោគជាមួយលោកសាខេ រួមទាំងអ្នកទារពន្ធផ្សេងៗទៀត ប៉ុន្ដែមានមនុស្សជាច្រើនរអ៊ូរទាំថា: "អ្នកនេះបរិភោគអាហារជាមួយអ្នកបាប"។

**តើលោកសាខេឆ្លើយយ៉ាងដូចម្ដេច ?**

ព្រះអម្ចាស់ ខ្ញុំនឹងចែកទ្រព្យសម្បត្តិចំនួនពាក់កណ្ដាលជូនអ្នកក្រីក្រ បើខ្ញុំទារពន្ធលើសកំនត់ខ្ញុំសងវិញមួយជាបី។ ព្រះយេស៊ូឆ្លើយតបថា ការសង្គ្រោះមកដល់ផ្ទះនេះហើយ។

លី សុវណ្ណា



# ព្រឹត្តិការណ៍ប្រចាំខែ



Photo: DR

## ទាហានឈុតខ្មៅថៃបំពានបោះទីតាំងក្បែរប្រាសាទព្រះវិហារ

មកត្រឹមថ្ងៃព្រហស្បតិ៍ ទី១៧ កក្កដានេះ ទាហានឈុតខ្មៅថៃនៅតែបន្តចូលមកបោះទីតាំងដោយខុសច្បាប់ក្នុងទឹកដីខ្មែរត្រង់ចំនុចវត្តភ្នំប្រាសាទដែលស្ថិតនៅចម្ងាយ២០០ម ខាងលិចប្រាសាទ ព្រះវិហារដែលធ្វើឱ្យចំនួនយោធាថៃកើនដល់៤០០នាក់ ។ លោកខៀវ កាញារិទ្ធ អ្នកនាំពាក្យរបស់រដ្ឋាភិបាល បានប្រាប់ឱ្យដឹងនៅថ្ងៃដដែលនេះថា សម្ដេចនាយករដ្ឋមន្ត្រីហ៊ុន សែន បានផ្ញើលិខិតផ្លូវការមួយច្បាប់តាមរយៈស្ថានទូតថៃប្រចាំកម្ពុជាជូនលោកនាយករដ្ឋមន្ត្រីថៃ សាម៉ាក់ ដោយសុំឱ្យថៃដកកងទ័ពរបស់ខ្លួនចេញពីវត្តភ្នំប្រាសាទ ក្រោយពេលនាយករដ្ឋមន្ត្រីទាំងពីរបានជួបគ្នាតាមទូរស័ព្ទរួចមក ។ សម្ដេចហ៊ុន សែន ព្រមឱ្យមានការជួបគ្នាមួយរវាងមន្ត្រីជាន់ខ្ពស់ខ្មែរ ទៀ បាញ់ ជាមួយនាយករដ្ឋមន្ត្រីថៃនៅថ្ងៃច័ន្ទ ទី២១ កក្កដា ក្នុងខេត្តស្រះកែវ ប្រទេសថៃ ។ លោកខៀវ កាញារិទ្ធ បានចាត់ទុកថា ការបង្កើនចំនួនទ័ពរបស់ថៃក្នុងតំបន់ប្រាសាទព្រះវិហារជារឿងខុសច្បាប់ហើយប្រទេសកម្ពុជាមានសិទ្ធិគ្រប់បែបយ៉ាងទាំងផ្លូវច្បាប់ និងការទូតដើម្បីការពារប្រទេស ។ ការជ្រៀតចូលរបស់ទាហានថៃបានធ្វើឡើងកាលពីថ្ងៃ១៥ កក្កដា ក្រោមលេសមកសុំដោះលែងព្រះសង្ឃថៃមួយអង្គ និងដូនជី២នាក់ ដែលបានលួចឆ្លងព្រំដែនចូលក្នុងទឹកដីខ្មែរដោយខុសច្បាប់ដើម្បីយកទង់ជាតិថៃមកដោតនៅលើប្រាសាទព្រះវិហារ ហើយត្រូវអាជ្ញាធរខ្មែរចាប់ខ្លួន ។ ប៉ុន្ដែក្រោយពេលដែលកម្ពុជាបានដោះលែងពួកគេទាំងនោះ ក្រោយពេលបំពេញឯកសាររួច ទាហានថៃមិនបានដកទៅវិញទេ ហើយថែមទាំងបង្កើនកម្លាំងខ្លួន ជារៀងរាល់ថ្ងៃថែមទៀត ។ គួររំឭកថា ការបំពានជ្រៀតចូលរបស់ថៃនេះបានធ្វើឡើងក្រោយពេលដែលប្រាសាទព្រះវិហារត្រូវបាន ចុះបញ្ជីជាបេតិកភណ្ឌពិភព-លោកកាលពីថ្ងៃទី៧ កក្កដា នៅទីក្រុងកេប៊ិក ប្រទេសកាណាដា ។

## FBI សហការណ៍ចាប់ឃាតកសម្លាប់អ្នកកាសែតមនសិការ

មកទល់ពេលនេះ សមត្ថកិច្ចនៅមិនទាន់ចាប់បានឃាតកដៃដល់បាញ់សម្លាប់អ្នកកាសែតមនសិការ លោកឃឹម សម្បូណ៌ និងកូនប្រុសនៅឡើយទេ ។ ក្នុងបញ្ហានេះ ភ្នាក់ងារស៊ើបអង្កេតសហព័ន្ធសហរដ្ឋអាម៉េ-រិកហៅថា FBI បានប្រកាសក្នុងសេចក្ដីថ្លែងការមួយរបស់ស្ថានទូតសហរដ្ឋអាម៉េរិកប្រចាំនៅកម្ពុជាកាលពីថ្ងៃ១៤ កក្កដាថា FBI បានត្រៀមខ្លួនជាស្រេចដើម្បីជួយក្នុងរឿងនេះបើមានការស្នើសុំពីរដ្ឋាភិបាលកម្ពុជា ។ ក្រសួងមហាផ្ទៃ បានបញ្ជាក់ជំហររបស់ខ្លួនថា ក្រសួងមិនបដិសេធកិច្ចសហប្រតិបត្តិការនេះទេ ប៉ុន្ដែសព្វថ្ងៃនេះ សមត្ថកិច្ចកំពុងដុតដៃ ដុតជើងខិតខំរកមុខជនដៃដល់និងបក្ខពួក ។ ស្ថានទូតអាម៉េរិកប្រចាំនៅកម្ពុជា បានអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ចាត់វិធានការចាំបាច់នានាដើម្បីចាប់ឃាតកដៃដល់មកផ្ដន្ទាទោសតាមច្បាប់ ។ លោកឃឹម សម្បូណ៌ និងកូនប្រុសត្រូវឃាតកមិនស្គាល់មុខ ២នាក់បាញ់សម្លាប់ ក្រោយពីចេញពីហាត់ប្រាណនៅពហុកីឡាដ្ឋានអូឡាំពិកកាលពីថ្ងៃ១១ កក្កដា ។

**រស់ ឌីណា**

## អ្នកស្រីអ៊ីនហ្គ្រីដ បេតាំងគួចាកផុតពីចំណាប់ខ្មាំងនៅកូឡុំប៊ី



Photo: DR

អ្នកស្រីអ៊ីនហ្គ្រីដ បេតាំងគួ ជនជាតិកូឡុំប៊ី សញ្ជាតិបារាំង ដែលត្រូវបានចាប់ជំរិតដោយពួកឧទ្ទាមហ្វាក់ (កងកម្លាំងបដិវត្តន៍ប្រទេសកូឡុំប៊ី) ត្រូវបានជួយសង្គ្រោះ ដោយកងទាហានប្រទេសកូឡុំប៊ី កាលពីថ្ងៃទី២ ខែកក្កដាកន្លងទៅ ចេញពីជំរំបង្ខូរឈាមរបស់ពួកឧទ្ទាមហ្វាក់ ដែលស្ថិតនៅក្នុងព្រៃដ៏ជ្រៅ ។

អ្នកស្រីបេតាំងគួបញ្ជាក់ថា ពេលនៅជាចំណាប់ខ្មាំង គឺពោរពេញដោយភាពរន្ធត់សម្រាប់ចំណាប់ខ្មាំងទាំងអស់ ។ អ្នកស្រី ដែលឥឡូវ មានវ័យ ៤៦ឆ្នាំ ត្រូវបានពួកឧទ្ទាមចាប់ចងនឹងច្រវ៉ាក់ជាញឹកញាប់ ធ្វើទារុណកម្ម និងបៀតបៀនកេរ្ដិ៍ខ្មាស់ ។ អ្នកស្រីបន្ថែមថា: "ពួកឧទ្ទាមទាំងនោះគួរឱ្យខ្ពើមរអើមជាខ្លាំង ប៉ុន្ដែខ្ញុំនៅលើកលែងទោសឱ្យពួកគេ" ។ អ្នកស្រីបេតាំងគួ ត្រូវគេបានចាប់ពង្រត់ នៅពេលអ្នកស្រីទៅធ្វើជាបេសកជនរបស់ប្រធានាធិបតីក្នុងការបញ្ចុះបញ្ចូលពួកឧទ្ទាម កាលពីឆ្នាំ២០០២ ។ ការមានសេរីភាពរបស់អ្នកស្រី ព្រមទាំងជនជាតិអាម៉េរិកបីនាក់ហើយ និងទាហាន ១១នាក់ផ្សេងទៀត ជាការវាយបករបស់រដ្ឋាភិបាលកូឡុំប៊ីប្រឆាំងនឹងពួកឧទ្ទាម ។ កាលពីថ្ងៃទី២០ ខែកក្កដា គឺជាបុណ្យឯករាជ្យកូឡុំប៊ីប្រជាជនកូឡុំប៊ីរាប់លាននាក់ ធ្វើបាតុកម្មប្រឆាំង ទាហានឧទ្ទាមហ្វាក់ និងអង្វរពួកគេដោះលែងចំណាប់នៅសល់ជាង៧៥០នាក់ទៀត ។

**អូម៉ែរ ហ្ស៊ីរ៉ាល់ដូ**

## ភូមា និងឥណ្ឌូនេស៊ី ប្រឈមខ្លាំងនឹងសារធាតុអាសេនិច

ការសិក្សាថ្មីមួយបានឱ្យដឹងថា តំបន់ដែនដីសណ្ដអេរ៉ាវ៉ាឌីនៅក្នុងប្រទេសភូមា ដែលរងគ្រោះដោយសារព្យុះកំណាច កាលពីពេលថ្មីៗ និងកោះស៊ូម៉ាត្រានៅប្រទេសឥណ្ឌូនេស៊ីប្រឈមមុខខ្ពស់នឹងសារធាតុអាសេនិច ។

បើយោងតាមការសិក្សាមួយ របស់វិទ្យាស្ថានវិទ្យាសាស្ត្រ និង-បច្ចេកទេសជលវិទ្យារបស់សហព័ន្ធស្វីស ក៏បានឱ្យដឹងថា ទឹកនៅក្នុងដីនៅតំបន់ដែនដីសណ្ដអេរ៉ាវ៉ាឌីនិងកោះសូម៉ាត្រា មានអត្រាសារធាតុអាសេនិច ដែលជាសារធាតុអាចបណ្ដាលឱ្យកើតជាជំងឺមហារីក និងជំងឺច្រើនប្រភេទទៀតដល់អ្នកប្រើប្រាស់ទឹកនោះ ។ លោកម៉ាយឃើល បើក (Michael Berg) អ្នកស្រាវជ្រាវនៅក្នុងវិទ្យាស្ថានខាងលើបានអះអាងប្រាប់អេភីថា ដោយផ្អែកទៅតាមទិន្នន័យ កម្រិតសារធាតុអាសេនិច នៅក្នុងទឹកក្រោមដីនៅក្នុងតំបន់នោះមានកម្រិតគួរឱ្យព្រួយបារម្ភមែនទែន ។

សារធាតុនេះ បានត្រូវរកឃើញមាននៅក្នុងទឹកក្រោមដី នៅក្នុងប្រទេសលើសពី ៧០% ហើយវាអាចប៉ះពាល់ប្រជាជនប្រមាណជា១៣៧លាននាក់ ក្នុងនោះក៏មានកម្ពុជានៅក្នុងបញ្ជីផងដែរ ។

**ខាន់ ភិរម្យ**

August-2008.qxd 7/29/2008 10:16 AM Page 6



# យុវជនម៉ាជីសអន្តរជាតិជួបជុំនៅព្រះសហគមន៍បាត់ដំបង

**សុជាតិ**

យុវជនយេស៊ូតហៅកាត់ថា ក្រុមម៉ាជីស ដែលមកពីប្រទេសអាឡឺម៉ង់ តៃវ៉ាន់ អូស្ត្រាលី និងប្រទេសកម្ពុជា មានសរុប២៥នាក់ បានជួបជុំគ្នានៅព្រះសហគមន៍បាត់ដំបងចំនួន ៥ថ្ងៃ គឺពីថ្ងៃទី៥ ដល់ទី១០ ខែកក្កដា ក្នុងគោលបំណងស្វែងយល់ពីគ្នាលើវប្បធម៌និងជំនឿសាសនា... ក្នុងនោះដែរក្រុមនេះមានសកម្មភាពផ្សេងៗ ដូចជា ចុះជួយកសិករនៅតាមស្រែចំការ សួរសុខទុក្ខប្រជាជនក្រីក្រ អ្នកជាប់ឃុំឃាំង និងក៏ចូលរួមដាំកូនឈើរួមជាមួយព្រះសង្ឃ ដើម្បីចូលរួមថែរក្សាបរិស្ថានផងដែរ។

រួមដំណើរជាមួយក្រុមចុះសួរសុខទុក្ខអ្នកភូមិ កញ្ញា សារ៉ា អាយុ២៦ឆ្នាំ គឺជាអ្នកដឹកនាំក្រុមម៉ាជីសនេះ បញ្ជាក់ថា ក្នុងដំណើរទស្សនកិច្ចមកប្រទេសកម្ពុជាលើកនេះ គឺស្វែងយល់អំពីវប្បធម៌ ជីវភាពរស់នៅ និងជំនឿគ្រីស្តសាសនា របស់បងប្អូនខ្មែរ។ ប្រធានក្រុមជនជាតិអាឡឺម៉ង់រូបនេះ បន្ថែមទៀតថា នាងបានរៀនជាច្រើន អំពីរបៀបរស់នៅរបស់ប្រជាជន ហើយប្រជាជនខ្មែរតែងមានភាពរួសរាយរាក់ទាក់ជាមួយក្រុមពួកនាងជានិច្ច។

ក្រុមម៉ាជីសនេះ បង្កើតឡើងដោយក្រុម សហជីវិនព្រះយេស៊ូ និងមានការជួបប្រជុំរយៈពេល២ឆ្នាំម្តង មុនទិវាយុវជនកាតូលិកពិភពលោក ១ឆ្នាំៗ។



Photo: DR

យុវជនក្រុមម៉ាជីស ថតរូបរួមគ្នាទុកជាអនុស្សាវរីយ៍នៅពេលពួកគេមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា

## ពលរដ្ឋភូមិចម្លាក់ចាប់អារម្មណ៍នឹងចង្ក្រានជីវឧស្ម័ន

កម្មវិធីអភិវឌ្ឍន៍ចង្ក្រានជីវឧស្ម័នក្នុងភូមិចម្លាក់ ឃុំចក ស្រុកអូររាំងឪ ខេត្តកំពង់ចាម កំពុងបានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់រដ្ឋាភិបាល ធនាគារអេស៊ីលីដា និងព្រះសហគមន៍កាតូលិកក្នុងភូមិនេះ។ លោកយែន យ៉េ អាយុ ៤២ឆ្នាំ ប្រជាជនក្នុងភូមិចម្លាក់ បានឱ្យដឹងថា ផ្ទះលោកមានចង្ក្រានជីវឧស្ម័ននេះមួយគ្រឿង។ វាមានប្រយោជន៍ច្រើន ដូចជាចម្អិនម្ហូបអាហារបានរហ័ស កាត់បន្ថយការចំណាយថវិកាក្នុងការទិញអុស និងប្រេងកាតសម្រាប់ចង្កៀង ដោយសារគេអាចបំប្លែងវាជាថាមពលអគ្គិសនីសម្រាប់តភ្ជាប់អំពូលតូចៗបាន។ ការប្រើប្រាស់ថាមពលថ្មីនេះមិនសូវបង្ករភាពកខ្វក់ដល់ចាន-ឆ្នាំងនោះឡើយ។ ជាពិសេសល្បាយដែល សល់អំពីការបំប្លែងឧស្ម័នក៏ត្រូវបានយកទៅធ្វើជីសម្រាប់ដាក់ស្រែផងដែរ។ លោកយ៉េ បន្ថែមទៀតថា វត្ថុធាតុដើមសម្រាប់បំប្លែងជាឧស្ម័ននោះ មានលាមកគោក្របី ជ្រូក និងមនុស្សជាដើម ប៉ុន្តែលាមកសត្វល្អជាង ព្រោះវាផ្តល់ថាមពលខ្លាំង។



Photo : Damo

ដាម៉ូ

## ឆ្នាំសន្តប៉ូលក្នុងព្រះសហគមន៍កាតូលិក

សម្តេចប៉ាប បេណេឌិក្ទូ ទី១៦ បានប្រកាសបើកឆ្នាំគ្រីស្តទូតប៉ូល ក្នុងឱកាសខួប២០០០ឆ្នាំ នៃកំណើតរបស់សន្តប៉ូល ឆ្នាំ២០០៨-២០០៩នេះ។

ឆ្លើយតបនឹងការប្រកាសបើកឆ្នាំសន្តប៉ូលនេះ ព្រះសហគមន៍ភូមិភាគភ្នំពេញ ផ្ញើលិខិតមួយទៅគ្រប់ព្រះសហគមន៍ អង្គការនានានៅក្នុងភូមិភាគដើម្បីប្រារព្ធឆ្នាំនៃសន្តប៉ូលកាលពីថ្ងៃទី១៦ មិថុនា កន្លងទៅ។ លោកអេមីល ដេតម្ប អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញបញ្ជាក់ក្នុងលិខិតនេះថា៖ "ឆ្នាំ ២០០៨-២០០៩ ខ្ញុំសូមអញ្ជើញបងប្អូនគ្រីស្តបរិស័ទទាំងអស់ក្នុងភូមិភាគភ្នំពេញ ត្រូវភ្ញាក់ខ្លួនយកជំនឿ និងសេចក្តីស្រឡាញ់ មកពាក់ធ្វើអាវក្រោះ ព្រមទាំងយកសេចក្តីសង្ឃឹម លើការសង្គ្រោះ មកពាក់ធ្វើជាមួកដែក (១ថេស្សាឡូនិក ៥,៨) ដើម្បីប្រកាសព្រះបន្ទូលព្រះជាម្ចាស់តាមរបៀបថ្មីដោយរួមជាមួយគ្រីស្តទូតប៉ូល"។ លោកបន្តថា : "រួមជាមួយលោកប៉ូល ប្រកាសព្រះបន្ទូលព្រះជាម្ចាស់ !" ពេញមួយឆ្នាំ គឺចាប់ពី ខែកញ្ញា ឆ្នាំ២០០៨ ដល់ខែមិថុនា ឆ្នាំ២០០៩" និងក៏មានផ្ញើជូនព្រះសហគមន៍ទាំងអស់ក្នុងភូមិភាគ ភ្នំពេញនូវសេចក្តីពន្យល់អំពីអត្ថបទទី២ សម្រាប់ថ្ងៃអាទិត្យ។

លី សុវណ្ណា

## បេសកកម្មដំបូងនៃក្រុមពេទ្យកាតូលិកកូរ៉េនៅកម្ពុជា

ក្រុមពេទ្យកូរ៉េចំនួន ២២នាក់ ដែលមានឈ្មោះថា "អ្នកបង្កើតសន្តិភាព" (PEACE MAKER ) បានចុះជួយពិនិត្យ និងព្យាបាលអ្នកជំងឺ ដូចជា ត្រចៀក ច្រមុះ បំពង់ក ធ្មេញ សើស្បែក និងជំងឺទូទៅដល់ប្រជាជន ចំនួន ៤កន្លែង ក្នុងខេត្តបាត់ដំបងដោយឥតបង់ថ្លៃ។សកម្មភាពនេះធ្វើឡើងឯសាលាបឋមសិក្សាព្រៃកន្តោរ ក្នុងពន្ធនាគារ ខេត្តបាត់ដំបង ព្រះសហគមន៍ចំណោម និងនៅព្រះសហគមន៍បាត់ដំបងកាលពីព្រឹកថ្ងៃទី១៧-២០ ខែកក្កដា ឆ្នាំ២០០៨នេះ។

ស្ថិតនៅក្នុងភាពជរា អាយុ៧៣ឆ្នាំ ហើយនិងមានជំងឺទឹកនោមផ្អែមផងនោះ ដូនចាស់ ពែន យុធដែលសព្វថ្ងៃនេះរស់ក្នុងភូមិសូភី១ ឃុំសូភីមួយ ស្រុកបាត់ដំបង ខេត្តបាត់ដំបង បានមានប្រសាសន៍ប្រាប់ឱ្យដឹងថា គាត់មកទីនេះដោយបានឮគេនិយាយ តៗគ្នា អំពីការព្យាបាលជំងឺដោយមិនគិតថ្លៃ។ ដូនចាស់ ក៏បានប្រាប់ទៀតថា ការព្យាបាល និងការទទួលរាក់ទាក់ របស់ក្រុម ក៏បានធ្វើឱ្យរូបគាត់ទទួលបាននូវភាពកក់ក្តៅ និងជំនឿចិត្ត ដោយលោកយាយបញ្ជាក់ថា ថ្នាំនេះនឹងជួយឱ្យគាត់ធូរស្បើយពីជំងឺ។

សុជាតិ





# ទិវាជួបជុំយុវជនពិភពលោក ប្រចាំឆ្នាំ២០០៨

**លី សុវណ្ណា**

យុវជនរាប់ម៉ឺននាក់ ដែលមកពីប្រទេសផ្សេងៗនៅទូទាំងពិភពលោក បានមកជួបជុំគ្នាក្នុងទិវាយុវជនពិភពលោកឆ្នាំ២០០៨ លើកទី២៣ នៅក្រុង ស៊ីដនី ប្រទេសអូស្ត្រាលី ក្រោមអធិបតីភាព សម្តេចប៉ាប បេណេឌិកទី១៦ កាលអំឡុងថ្ងៃទី១៥ ដល់២០ ខែកក្កដា កន្លងទៅនេះ។

ក្នុងលិខិតសម្តេចប៉ាបបេណេឌិក ទី១៦ នៅក្នុងទិវាយុវជនពិភពលោកឆ្នាំនេះ សម្តេចប៉ាបស្នើឱ្យយុវជនរិះគិតពីប្រធានបទ "ព្រះវិញ្ញាណដ៏វិសុទ្ធ" "អ្នករាល់គ្នានឹងទទួលនូវឫទ្ធានុភាពមួយ គឺព្រះវិញ្ញាណដ៏វិសុទ្ធនឹងមកសណ្ឋិតលើអ្នករាល់គ្នា។ អ្នករាល់គ្នានឹងធ្វើជាទីបន្ទាល់នៃខ្ញុំ..." (កិច្ចការ១,៨)។ លិខិតនេះបន្តទៀត មានមនុស្សច្រើន មិនទាន់បានទទួលដំណឹងល្អអំពីព្រះយេស៊ូនៅឡើយ។ ព្រះវិញ្ញាណដ៏វិសុទ្ធជ្រើសរើសយើងឱ្យមានជីវិត ក្តីស្រឡាញ់ និងសេចក្តីពិត និងឱ្យយើងស្គាល់ព្រះយេស៊ូផងដែរ។

ក្នុងជំនួបជាមួយយុវជនរាប់ម៉ឺននាក់ សម្តេចប៉ាបក៏បានហៅការជួបជុំគ្នានេះជាការរួបរួមក្នុងជំនឿនិងជាសារៈសំខាន់របស់ព្រះសហគមន៍។ សម្តេចប៉ាបសុំឱ្យអ្នកជឿទាំងអស់តស៊ូ និងចាកចេញអំពីគំនាបនៃសង្គមសម័យទំនើបនេះ។ នៅក្នុងពេលនោះដែរ សម្តេចប៉ាប ក៏បានជំរុញផងដែរឱ្យយកចិត្តទុកដាក់ចំពោះបរិស្ថានក្នុងលោកនេះ ដែលកំពុងមានបញ្ហាច្រើនជាសញ្ញាដែលធ្វើឱ្យភ័យខ្លាច និងព្រួយបារម្ភ ដូចជាការសឹករេចរឹលរបស់ផែនដី ការកាប់បំផ្លាញព្រៃឈើ និងការប្រើប្រាស់ខ្ជះខ្ជាយនៃវត្ថុធាតុដើមក្រោមដី និងនៅក្រោមសមុទ្រជាដើម។

មិនត្រឹមតែប៉ុណ្ណោះ លោកក៏បានសុំឱ្យគ្រីស្តបរិស័ទកាតូលិកទាំងរួមគ្នាប្រឆាំងដាច់ខាតចំពោះនិន្នាការដែលនាំឱ្យមានការរំលោភផ្លូវភេទ និងអំពើហិង្សាតាមគ្រប់រូបភាពមានខ្សែភាពយន្ត និងអ៊ិនធឺណែត -ល-។ ជាក់ស្តែងនៅក្នុងទិវា ដ៏វិសេសវិសាលនេះ "លោកក៏បានជួបក្រៅផ្លូវការនៅវិសាលវិហារ សន្តម៉ារីនៅកណ្តាល ទីក្រុងស៊ីដនីដើម្បីសុំអភ័យទោសស្រី និងក្រុមគ្រួសារដែលរងគ្រោះដោយរំលោភផ្លូវភេទអំពីសំណាក់បព្វជិតកាតូលិកនៅក្នុងប្រទេសអូស្ត្រាលី។ លោកក៏បានធ្វើការជួបផ្ទាល់ជាមួយជនរងគ្រោះម្នាក់ម្តងៗ"។ បើតាមសេចក្តីរាយការណ៍របស់ News.Ltd បានឱ្យដឹងថា លោកជួបជាមួយជនរងគ្រោះជាលក្ខណៈឯកជន ដោយការ "គោរព និងដោយទឹកចិត្តស្មោះស្ម័គ្រ និងការតាំងចិត្តប្រកបដោយការរំភើបរំជួលចិត្ត"។ ប៉ុន្តែបុរសជាឪពុកនារីរងគ្រោះ អះអាងថា ការសុំអភ័យទោសពីសំណាក់សម្តេចប៉ាបនេះ គឺធ្វើឱ្យមានការខកចិត្តទៅវិញទេ ព្រោះគ្មានការប្រតិបត្តិដល់ជនរងគ្រោះ។

មុនការចាកចេញពីសម្តេចប៉ាបបានប្រារព្ធពិធីដើម្បីសុំអភ័យទោសដោយចំហចំពោះជនរងគ្រោះ ដែលរងការរំលោភផ្លូវភេទ ពីសំណាក់ បព្វជិតទាំងអស់ក្នុងនោះមានប្រទេសអូស្ត្រាលីនេះដែរ។

### ទិវាយុវជនពិភពលោក និងទីកន្លែងរៀបចំ

**ទិវាយុវជនពិភពលោកបានបង្កើតឡើងដោយអតីតសម្តេចប៉ាបយ៉ូហាន ប៉ូលទី២ ឆ្នាំ១៩៨៤ នៅក្រុងរ៉ូម អ៊ីតាលី មានអ្នកចូលរួមចំនួនប្រមាណ ៣០០០០០នាក់។ នៅឆ្នាំ១៩៨៥ ធ្វើនៅទីក្រុងរ៉ូម អ៊ីតាលីទៀត។ នៅឆ្នាំ១៩៨៧ ធ្វើនៅប្រទេសអាហ្សង់ទីន។ នៅឆ្នាំ១៩៨៩ ធ្វើនៅប្រទេសអេស្ប៉ាញ។ នៅឆ្នាំ ១៩៩១ ធ្វើនៅប្រទេសប៉ូឡូញ។ នៅឆ្នាំ១៩៩៣ ធ្វើនៅសហរដ្ឋអាមេរិក។ នៅឆ្នាំ១៩៩៥ ធ្វើនៅប្រទេសហ្វីលីពីន។ នៅឆ្នាំ១៩៩៧ ធ្វើនៅប្រទេសបារាំង។ នៅឆ្នាំ២០០០ ធ្វើនៅអ៊ីតាលី។ នៅឆ្នាំ២០០២ ធ្វើនៅកាណាដា។ នៅឆ្នាំ២០០៥ ធ្វើនៅអាល្លឺម៉ង់ ដែលសម្តេចប៉ាបបេណេឌិកទី១៦ ធ្វើជាអធិបតី។ ឆ្នាំ២០០៨នេះ ធ្វើនៅអូស្ត្រាលី និងទិវាយុវជនពិភពលោក ឆ្នាំ២០១១ ធ្វើនៅក្រុងម៉ាឌ្រីដ អេស្ប៉ាញ។**



សម្តេចប៉ាបបេណេឌិកទី១៦



យុវជនពិភពលោកជួបជុំគ្នា



ទេសភាពទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី មើលពីលើអាកាស

Photos : DR

August-2008.qxd 7/29/2008 10:16 AM Page 8



# ការងារស្ម័គ្រចិត្តរបស់យុវជនខ្មែរ នៅឯក្រៅប្រទេស

**ឡុង សម្ផស្ស**



សិក្ខាសាលាស្ដីអំពីការងារស្ម័គ្រចិត្តនៅក្រៅប្រទេស នៃអង្គការសម្ពន្ធយុវជនអន្តរជាតិកម្ពុជា IYF

ការចែករំលែកបទពិសោធន៍ជាមួយអ្នកដទៃ គឺជាទំនាក់ទំនងដ៏សំខាន់ក្នុងការរស់នៅប្រកប ដោយក្ដីសុខសាន្ត ដែលការចែករំលែកនេះគឺតែងកើតមានពីមនុស្សម្នាក់ទៅម្នាក់ទៀត។ លោកអ៊ី សេងលីជានាយកកម្មវិធីប្រចាំអង្គការសម្ពន្ធយុវជនអន្តរជាតិកម្ពុជា (IYF) បានថ្លែងថា: "អង្គការសម្ពន្ធយុវជនអន្តរជាតិកម្ពុជាជាអង្គការអន្តរជាតិមួយដែលមានសាខានៅប្រមាណ ៨៥ប្រទេស ជុំវិញពិភពលោក ហើយបានដំណើរការនៅប្រទេសកម្ពុជា តាំងពីឆ្នាំ២០០៤មក។ អង្គការបង្កើតឡើងក្នុងគោលបំណងជួយបណ្ដុះបណ្ដាលយុវជនឱ្យឆ្ពោះទៅមុខក្នុងភាពជាអ្នកដឹកនាំ ដោយមានកម្មវិធីច្រើនសម្រាប់ពួកគេ ដូចជា សកម្មភាព-បេសកកម្មអភិរក្សបរិស្ថាន ការសិក្សាភាសាបរទេស ផ្លាស់ប្ដូរប្រពៃណីវប្បធម៌តាមរយៈការសម្ដែង និងប្រឹក្សាយោបល់ ក្នុងការទំនាក់ទំនងនឹងនិស្សិតបរទេស ។ល។

លោកសេងលី បានបន្ថែមថា: "កម្មវិធីមួយ ដែលអង្គការកំពុងរៀបចំ គឺ GoodNews Corps ដែលនឹងផ្ដល់ឱកាសដល់យុវជនបានចូលរួមដកស្រង់បទពិសោធន៍ ជាមួយនិងយុវជនបរទេសតាមរយៈការស្ម័គ្រចិត្តបម្រើការងារ នៅក្រៅប្រទេសរយៈពេលមួយឆ្នាំ។ កម្មវិធីនេះមានគោលបំណងជួយយុវជនឱ្យចេះចែករំលែកចិត្តជាមួយអ្នកដទៃ ដោយរកឱ្យឃើញនូវសុភមង្គលដ៏ពិតប្រាកដ ដែលមិនមែនបានមកពីការបម្រើខ្លួនឯងទេ ផ្ទុយទៅវិញ គឺបានមកពីការបម្រើអ្នកដទៃ។ កម្មវិធីនេះក៏ជួយយុវជនក្នុងការពង្រឹងចិត្ត និងគំនិតរបស់ពួកគេតាមរយៈកម្ម-វិធីផ្សេងៗ ជាច្រើន ដែលបង្រៀន ឱ្យមានការតស៊ូ និងស្មារតីប្រកួតប្រជែង ដើម្បីក្លាយខ្លួនទៅជាអ្នកដឹកនាំដ៏ល្អម្នាក់នាពេលអនាគត"។

យុវជនគ្រប់ៗរូបមានអាយុក្រោម៣០ឆ្នាំ ត្រូវបានលើកទឹកចិត្តឱ្យចូលរួមកម្មវិធីនេះ។ ពួកគេត្រូវជានិស្សិតកំពុងសិក្សានៅសកលវិទ្យាល័យ ដែលគ្មានបញ្ហាក្នុងការឆ្លងដែន និងជាអ្នកដែលមានសុខភាពល្អទាំងខាងរូបកាយ និងចិត្ត។

អង្គការសម្ពន្ធយុវជនអន្តរជាតិកម្ពុជា គឺមានទីតាំងស្ថិតនៅផ្ទះលេខ៣៤៥ ផ្លូវ១៣ នាភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឬក៏អាចទំនាក់ទំនង តាមទូរស័ព្ទ: ០២៣ ៨៨៣៦១០ ០១៧ ៦២២០៧៣ ឬ០១៧ ៨៦៧៨២០ ។

## ស៊ាន សាវី : IYF ជួយខ្ញុំឱ្យចេះគិតសម្រាប់អ្នកដទៃ

កញ្ញាស៊ាន សាវី អាយុ ២៧ឆ្នាំ គឺមានស្រុកកំណើតនៅខេត្តសៀមរាប។ សព្វថ្ងៃនេះ កញ្ញាជាសមាជិកម្នាក់ក្នុងក្រុមយុវជន ប្រចាំនៅអង្គការសម្ពន្ធយុវ-ជនអន្តរជាតិកម្ពុជា។

ទាក់ទងទៅនឹងការងារស្ម័គ្រចិត្ត នៅក្រៅប្រទេស កញ្ញាបានរៀបរាប់ថា: "កម្មវិធីនេះសម្រាប់និស្សិតស្ម័គ្រចិត្តទៅធ្វើការក្រៅប្រទេស។ នេះគឺជាលើកទីមួយ ដែលអង្គការផ្ដល់ឱកាសឱ្យយុវជន យុវនារីពីប្រទេសកម្ពុជាឱ្យទៅបំពេញការងារស្ម័គ្រចិត្តនៅបរទេសតាមប្រទេសសាខារបស់អង្គការ"។

ឆ្លងតាមបទពិសោធន៍នៃកញ្ញាផ្ទាល់ ដែលធ្លាប់បានចូលរួមកម្មវិធីប្រជុំយុវជននៅក្រៅប្រទេស ក៏បានឱ្យដឹងថា: "ចាប់តាំងពីខ្ញុំបានចូលរួមក្នុងក្រុមយុវ-ជនរបស់អង្គការនេះកាលពីឆ្នាំ២០០២មក បានធ្វើឱ្យជីវិតរបស់ខ្ញុំមានការផ្លាស់ប្ដូរជាច្រើនដោយសារខ្ញុំបានឆ្លងកាត់នូវសិក្ខាសាលាGoodNews Corps របស់អង្គការ។ ការផ្លាស់ប្ដូរទាំងនោះ គឺមានដូចជា


Photos : L. Samphors

ការផ្លាស់ប្ដូរឥរិយាបទនៅក្នុងសកម្មភាពសម្រាប់ការទំនាក់ទំនង ការចែករំលែកនូវចិត្តគំនិតជាមួយនឹងមិត្តភ័ក្ដ្រ និងការបន្ទាបខ្លួនឱ្យមានការចូលចុះជាមួយអ្នកដទៃនៅគ្រប់កាលៈទេសៈជាដើម។ កាលពីមុន ខ្ញុំមានចិត្តចង្អៀតចង្អល់នឹងអ្នកដទៃ ពោលគឺធ្វើអ្វីៗ សម្រាប់តែខ្លួនឯងដោយមិនបានគិតគូរដល់អ្នកដទៃនោះឡើយ។ តែទោះជាយ៉ាងណាក្រោយពីបានចូលរួមនៅក្នុងកម្មវិធីនេះមក ខ្ញុំចេះអត់ធ្មត់ចំពោះរាល់ការលំបាកៗទាំងឡាយ ចេះផ្ដល់សេចក្ដីស្រឡាញ់ចំពោះអ្នកដទៃ ចេះបើកចិត្តរៀនទទួលយកនូវបទពិសោធន៍ពីអ្នកដទៃ ហើយជាពិសេសគឺចេះផ្ដល់តម្លៃចំពោះខ្លួនឯង ដោយធ្វើការអភិវឌ្ឍន៍ខ្លួនឱ្យមានការរីកចម្រើនទៅមុខជាលំដាប់"។






សុខាណា (រូបឆ្វេង) និងវ៉ាន់នី (រូបស្ដាំ) មានបទពិសោធន៍ជាមួយសន្ដេវាសិកដ្ឋានវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
Photo : Ann-Laure Porée

# ជីវិតរស់នៅយ៉ាងមនោរម្យក្នុងសន្ដេវាសិកដ្ឋាន

**អាន ឡូរ៉ែ ប៉ូរ៉េ**

យុវនារីប្រមាណ ៤០នាក់ និងយុវជន ១០០ប្លាយ-នាក់ ដែលចាកចេញពីភូមិកំណើត និងបានមករស់នៅក្នុងសន្ដេវាសិកដ្ឋាន នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) មានដើមកំណើតពីគ្រួសារក្រីក្រនៅតាមខេត្ត។ ពួកគេត្រូវបានជ្រើសរើស ឱ្យចូលមកស្នាក់នៅ ផ្អែកតាមលក្ខណៈវិនិច្ឆ័យសង្គម និងតាមការសម្ភាសន៍។ ពួកគេគ្មានហេតុផលដើម្បីផ្លាស់ប្ដូរទៅពិភពខាងក្រៅឡើយ។ សន្ដេវាសិកដ្ឋាននេះ គឺប្រៀបបានដូចជាគ្រួសារទីពីររបស់ពួកគេដែរ។

វ៉ាន់នី ពន្យល់ថា: "មិត្តភ័ក្ដ្រដែលស្នាក់នៅបន្ទប់ជាមួយខ្ញុំប្រៀបដូចជាបងប្អូនស្រីរបស់ខ្ញុំ។" វ៉ាន់នី ជាយុវនារី ដែលបានទទួលនូវសញ្ញាបត្ររួចហើយនៅអាយុ២៣ឆ្នាំ ហើយដែលទើបបានចាកចេញពីការរស់នៅក្នុងសន្ដេវាសិកដ្ឋានបន្ទាប់ពីស្នាក់នៅទីនោះរយៈពេល៤ឆ្នាំមក។ សម្រាប់អ្នកនាង ប្រព័ន្ធនេះបង្ហាញអំពីសារៈប្រយោជន៍លំដាប់ទីមួយ គឺនិស្សិតអាចជួយគ្នា និងមានសាមគ្គីភាពជាមួយគ្នា។

វ៉ាន់នីបន្ថែមថា: "ខ្ញុំបានចងមិត្តជាច្រើន។ តែឥឡូវខ្ញុំក៏ជឿថា ខ្ញុំធ្វើការងារបានកាន់តែច្រើន នៅពេលខ្ញុំស្នាក់នៅម្នាក់ឯង។ ប៉ុន្តែបើរស់នៅក្នុងសន្ដេវា-សិកដ្ឋាន យើងអាចរំឭកមេរៀនជាមួយគ្នា។ យើងចែករំលែកគំនិតរបស់យើង និងបទពិសោធន៍របស់យើងផងដែរ។ យើងបានសិក្សាផងដែរដើម្បីស្គាល់រឿងរ៉ាវជាច្រើនអំពីប្រពៃណី និងរបៀបរបបរស់នៅតាមខេត្តផ្សេងៗតាមរយៈនិស្សិតដែលបានមកស្នាក់នៅ"។ សាមគ្គីភាពគឺមានលក្ខណៈជាទូទៅ។ តួយ៉ាងបើនិស្សិតណាម្នាក់មានបញ្ហាខាងលុយកាក់ គាត់នឹងត្រូវមិត្តភក្ដិអញ្ជើញឱ្យហូបអាហារ ហើយគាត់អាចស្វែងរកការងារតូចមួយក្នុងសន្ដេវាសិក-ដ្ឋានដើម្បីធ្វើចេញសងនៅចុងសប្ដាហ៍។

សន្ដេវាសិកដ្ឋាននេះជាកន្លែងបម្រុងទុក និងអាចឱ្យអ្នកស្នាក់នៅអាចធ្វើការសិក្សារៀនសូត្រក្នុងលក្ខ-ខណ្ឌប្រសើរបំផុត។ វាត្រូវបានគេសាងសង់នៅជិតសកលវិទ្យាល័យ ដើម្បីឱ្យនិស្សិតមិនចាំបាច់ធ្វើការចំណាយសោហ៊ុយច្រើន ដើម្បីធ្វើដំណើរទៅរៀន។ ការស្នាក់នៅមិនចាំបាច់ចំណាយលុយ ទាំងទឹក និងទាំងភ្លើងផងដែរ ប៉ុន្តែនិស្សិតដែលស្នាក់នៅត្រូវតែកម្រិតនូវការប្រើប្រាស់របស់ខ្លួន យ៉ាងច្បាស់លាស់ គឺគេអាចប្រើតែទឹក ១០ម៉ែត្រ³ និងភ្លើង៣០គីឡូវ៉ាត់សម្រាប់ម្នាក់ៗក្នុងមួយខែ។ តាមធម្មតា នារីច្រើនធ្វើម្ហូបហូបខ្លួនឯង ចំណែកប្រុសៗមិនធ្វើទេ។ ប៉ុន្តែជួនកាល ពួកគេធ្វើម្ហូបដោយខ្លួនឯងដែរជាពិសេសនៅថ្ងៃបុណ្យ។ ប៉ុន្តែវ៉ាន់នីរៀបរាប់ថា: "នេះធ្វើឱ្យបាត់បង់ពេលវេលាច្រើនណាស់ បើសិនជាយើងដើរផ្សារ ដើរដើម្បីទិញឥវ៉ាន់ ហើយត្រឡប់មកវិញធ្វើការចម្អិន រួចបរិភោគនោះ។ ដូច្នេះយើងក៏ច្រើនតែទៅហូបអាហារតាមកន្លែងលក់សាធារណៈ"។

នារី និងបុរស គឺមិនបានទទួលការយកចិត្តទុកដាក់ដូចគ្នាទាំងស្រុងនោះទេ។ ប្រុសៗស្នាក់នៅ ៤នាក់នៅក្នុងមួយបន្ទប់ ចំណែកស្រីៗមួយបន្ទប់ មាន ២នាក់ ជាមួយគ្រែគេង ៣ ឬ៤។

វ៉ាន់នីអួត និងសើចថា: "អគារសម្រាប់ស្រីៗ ស្នាក់នៅ គឺមានសភាពគួរឱ្យមនោរម្យច្រើនជាង ព្រោះស្រីៗថែទាំ និងយកចិត្តទុកដាក់រៀបចំ ជាងប្រុសៗដែលច្រើនតែខ្ជិល។" សុខាណានិស្សិតអេឡិចត្រូ-និច និងថាមពលមានការលំបាក នឹងនិយាយផ្ទុយពីនេះណាស់។ លោកបន្តថា: "ប្រុសៗ មិនមានសិទ្ធិនឹងចូលខាងអគាររបស់ស្រីៗទេ។ នេះជាការហាមឃាត់ជាផ្លូវការ។ គឺមានអ្នកយាមម្នាក់យាមនៅទីនោះ ក្នុងខណៈដែរអនុរក្សម្នាក់ទៀត ជាអ្នកតាមដានការគោរពបទបញ្ជានៃការរស់នៅ។

នៅក្នុងសន្ដេវាសិកដ្ឋាននេះ អារម្មណ៍របស់និស្សិតវិលវល់មិនឆ្ងាយ អំពីគ្រួសាររបស់គេនោះឡើយ។ ពួកគេត្រឡប់ទៅផ្ទះកំណើតវិញ នៅថ្ងៃចុងសប្ដាហ៍ ឬពេលមានបុណ្យទានម្ដងៗ។ តែបើពួកគេមិនទៅ ពួកគេរៀបចំដំណើរចេញដើរលេងជាមួយមិត្តភក្ដិទៅលេងវត្ត ឬក៏កន្លែងផ្សេងៗ។ វ៉ាន់នីដែលស្គាល់ និងស្រង់យកមេរៀនជីវិតអស់រយៈពេល ៤ឆ្នាំ នៅសន្ដេវាសិកដ្ឋាននេះ បានបន្ថែមថា: "មិនត្រូវខ្លាចការស្នាក់នៅទីនោះទេ។ នេះគឺជាមធ្យោបាយមួយល្អដើម្បីដឹងថា គេនឹងទៅទីណា"។

August-2008.qxd 7/29/2008 10:16 AM Page 10

## បទយកការណ៍

# អំពើរំលោភសេពសន្ថវៈកើនឡើង និងមូលហេតុនៃបញ្ហា

**ខាន់ ភីរម្យ**




អំពើហិង្សា ឬការស្រវឹង ជាកត្តាមួយជំរុញឱ្យមនុស្សអាចប្រព្រឹត្តនូវអំពើដ៏លាមក

Photo : Y. Soksan

នេះគឺជាសំណួរដែលត្រូវបានឆ្លើយនៅលើទំព័រសារព័ត៌មានប្រចាំថ្ងៃជាភាសាខ្មែរដែលចេញផ្សាយនៅក្នុងប្រទេសកម្ពុជា ។ លើទំព័រកាសែតកម្រាស់ ២៤ ទំព័រកាសែតរស្មីកម្ពុជា កោះសន្តិភាព និងកម្ពុជាថ្មី ព័ត៌មានអំពីការចាប់រំលោភ បានចេញផ្សាយស្ទើរតែរៀងរាល់ថ្ងៃ ដែលនេះជាភ័ស្តុតាងមួយបញ្ជាក់ថា អំពើនេះកំពុងកើតមាននៅក្នុងសង្គមខ្មែរ ស្ទើរតែរាល់ថ្ងៃ ហើយករណីរឹតតែធ្ងន់ធ្ងរទៅទៀតនោះ គឺមានបាតុភូតនៃអំពើចាប់រំលោភនៅក្នុងចំណោមសាច់ញាតិលោហិតរបស់ជនរងគ្រោះ ផ្ទាល់តែម្តង ដែលជាហេតុធ្វើឱ្យអ្នកជំនាញការ ខាងសង្គមមួយចំនួនអះអាងថា នេះគឺជាភ័ស្តុតាងមួយនៃការធ្លាក់ចុះតម្លៃសីលធម៌ដ៏ខ្លាំងក្លាក្នុងសង្គម ។

នៅក្នុងអំឡុងរយៈពេល ពីថ្ងៃទី០៣ ដល់ថ្ងៃទី១០ ខែកក្កដា អំពើរំលោភដែលកាសែត ជាភាសាខ្មែរប្រចាំថ្ងៃបានចេញផ្សាយ មានចំនួនយ៉ាងហោច ៩ អត្ថបទនៅក្នុងនោះកោះសន្តិភាព មានចំនួន៩ នៅកម្ពុជាថ្មី និងរស្មីកម្ពុជាចំនួន២ ។ បើយោងទៅតាមរបាយការណ៍របស់គណៈកម្មាធិការអ៊ុកផាតកម្ពុជា ដែលបានតាមដានកាសែតធំៗ នៅប្រទេសកម្ពុជា នៅក្នុងរយៈពេល ២ត្រីមាស កន្លងទៅនេះ គេបានរកឃើញ ករណីរំលោភសេពសន្ថវៈ រហូតដល់ទៅ ១៣១ករណី ហើយក៏មានជនរងគ្រោះចំនួន ១៤២ នាក់ នៅក្នុងនោះ ៧៩នាក់គឺជាអនីតិជន ៦១នាក់ គឺជាកុមារដែលមានអាយុក្រោម ១៥ឆ្នាំ ហើយជនសង្ស័យមានរហូតដល់ទៅ ១៨១នាក់ ។ ក្រៅពីនេះ គេក៏បានរកឃើញផងដែរថា មានកុមារ៧នាក់ ត្រូវបានរំលោភដោយឪពុកបង្កើត ឬក៏ឪពុកចុង ៣នាក់ រំលោភដោយបងប្អូនជីដូនមួយ ហើយ៣២នាក់ គឺត្រូវបានរំលោភដោយអ្នកជិតខាង ។

**យោបល់អ្នកជំនាញ**

លោកស្រីជា វណ្ណាត ជាអតីតប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ក៏មានប្រសាសន៍ថា នេះគឺជាអំពើអសីលធម៌ដ៏ធ្ងន់ធ្ងរដែលសង្គមកម្ពុជាប្រកបដោយវប្បធម៌ថ្លៃថ្នូរ គឺមិនអាចទទួលយកបាន ។ ការកើនឡើងនៃអំពើចាប់រំលោភ ពិសេសនៅក្នុងចំណោមសាច់សាលោហិត ជាសញ្ញានៃការធ្លាក់ចុះ នៃតម្លៃសីលធម៌របស់ប្រទេសកម្ពុជា ។

### ករណីឪពុករំលោភកូននៅកំពង់ធំ

**តាមអត្ថបទមួយចុះផ្សាយនៅលើទំព័រកាសែតកោះសន្តិភាព កាលពីថ្ងៃទី០៣ កក្កដា ឆ្នាំ២០០៨ បានឱ្យដឹងថា នៅក្នុងភូមិកោះតាពៅ ឃុំផាត់សណ្តាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បុរសម្នាក់ឈ្មោះ កែវ សារិន អាយុ៤៩ឆ្នាំ បានត្រូវប៉ូលិសចាប់ខ្លួនពីបទចោទប្រកាន់ថា បានរំលោភកូនស្រីបង្កើត ដែលមានអាយុទើបតែ១១ឆ្នាំប៉ុណ្ណោះ។ រឿងរ៉ាវនេះបានកើតមានឡើងកាលពីថ្ងៃទី២៦ មិថុនា ឆ្នាំ២០០៨ ក្រោយពេលដែលបុរសនោះស្រវឹងជោគជាំបន្ទាប់ពីត្រឡប់មកពីជួយបុណ្យខ្មោចគេនៅក្នុងភូមិ។ ពេលនេះ ជននេះបានចាប់កូនស្រីចងដៃចងជើងញ៉ុកមាត់មុននឹងរំលោភនៅក្នុងពេលដែលម្តាយរបស់កុមារីមិននៅផ្ទះ។**

លោកអ៊ី រតនា បណ្ឌិតសង្គមវិទ្យា មានប្រសាសន៍ថា អំពើរំលោភដោយសាច់ញាតិ គឺជាបញ្ហា និងជារោគសង្គមកម្ពុជាមួយដែលត្រូវដោះស្រាយ ។

**តួលេខនៃអំពើរំលោភសេពសន្ថវៈ**

លោកស្រីនុព្វសារិនស្រីរ័ត្ន អគ្គលេខាធិការអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានឱ្យដឹងថា តាមស្ថិតិរបស់អង្គការ អំពើរំលោភសេពសន្ថវៈ គឺមានការកើនឡើង ពីឆ្នាំ២០០៦ ទៅឆ្នាំ២០០៧ ហើយនៅឆ្នាំ២០០៨ តួលេខដូចជា នៅថេរ ។ ឆ្នាំ២០០៦ ការរំលោភមាន ២០២ករណី នៅឆ្នាំ២០០៧ មាន ២២១ករណី ដោយឡែកនៅក្នុងឆ្នាំ២០០៨ គឺនៅថេរ ។ លោកស្រីក៏បន្តទៀតថា សព្វថ្ងៃអំពើរំលោភសេពសន្ថវៈភាគច្រើនជាសកម្មភាពជាក្រុម ហើយអ្វីដែលជាប្រការរឹតតែសោកសង្រេង ជាងនេះទៅទៀតនោះ គឺមានករណីរំលោភដែលកើតមាននៅក្នុងចំណោមសាច់ញាតិខ្លួនឯង ។

លោកស្រីបានបន្តទៀតថា: "ជីតារំលោភចៅ ឪពុករំលោភកូន ឪពុកចុងរំលោភកូនដើម បងរំលោភប្អូន គឺសុទ្ធសឹងតែជាករណីដែលអង្គការរបស់យើងធ្លាប់ជួបទាំងអស់" ។



លោកប៉ិ វណ្ណៈ អ្នកឃ្លាំមើលការរំលោភសិទ្ធិកុមារកម្រិតខ្ពស់របស់អង្គការលីកាដូ មានប្រសាសន៍ថា ការរំលោភសេពសន្ថវៈ គឺជាអំពើមួយដ៏ឃោរឃៅ ហើយកំពុងតែកើតមានជាបន្តបន្ទាប់នៅក្នុងសង្គមសព្វថ្ងៃ ។ លោកបន្តទៀតថា ពីឆ្នាំ២០០៦ មកដល់ ៦ខែ ដើមឆ្នាំ២០០៨ ចំនួនករណីរំលោភពុំមានការថយចុះឡើយ មានតែថេរ និងកើនឡើងប៉ុណ្ណោះ ។ រឿងថយនៅមិនទាន់រកឃើញនៅឡើយ ។ ក្នុងឆ្នាំ ២០០៦ ការរំលោភមាន១៩៣ករណី ។ ឆ្នាំ២០០៧ មាន ២០០ករណី ក្នុងនោះ មានករណីជីតារំលោភចៅស្រីបង្កើត បងប្រុសរំលោភប្អូន បងជីដូនមួយរំលោភប្អូនស្រីជីដូនមួយ និងឪពុកចុងរំលោភកូនដើម មានមួយៗករណី ។ ដោយឡែក នៅក្នុង៦ខែដំបូងនៃឆ្នាំ២០០៨ អំពើរំលោភសេពសន្ថវៈ មានចំនួន៥៤ករណី ក្នុងនោះជនរងគ្រោះ មាន៥៧នាក់ តែជនល្មើសមានរហូតដល់៨២នាក់ ។ ក្នុងចំណោមនោះ ករណីរំលោភដោយសាច់ញាតិ មានចំនួន ៣ ករណី គឺឪពុកបង្កើតរំលោភកូនស្រីឯង មួយករណី ឪពុកចុងរំលោភកូនដើមមួយករណីហើយបងជីដូនមួយរំលោភប្អូនស្រីជីដូនមួយ មួយករណី ។ ក្រៅពីនេះ នៅមានករណីខ្លះទៀតជាការ រំលោភជាក្រុម គឺមាន៥ករណី ដោយជនរងគ្រោះ គឺមានតែ៦នាក់ទេ ប៉ុន្តែជនល្មើសមានរហូតដល់ទៅ ៣៣នាក់ ។

លោកបានបន្តទៀតថា ស្ថានភាពអំពើរំលោភកាន់តែមានសភាពធ្ងន់ធ្ងរទៅៗ ហើយជនល្មើស ហើយនិងជនរងគ្រោះកាន់តែក្មេងទៅៗ ។ ជាក់ស្តែង នៅក្នុងដើមឆ្នាំ២០០៨នេះជនល្មើសខ្លះមានអាយុត្រឹមតែ១៦ឆ្នាំ តែប៉ុណ្ណោះ ចំណែកឯជនរងគ្រោះ មានចាប់ពី ៥ឆ្នាំឡើងទៅ ។ លោកបញ្ជាក់ថា : "តម្លៃនៃសីលធម៌កំពុងតែធ្លាក់ចុះទាំងចាស់ទាំងក្មេង" ។

**មូលហេតុ**

ពាក់ព័ន្ធទៅនឹងការកើនឡើង នៃអំពើរំលោភសេពសន្ថវៈ និងសកម្មភាពរំលោភនៅក្នុងចំណោមសាច់សាលោហិតនោះ ក្រុមអ្នកជំនាញការ បានធ្វើការស្តីបន្ទោសនិងផ្តោតជាសំខាន់ទៅលើភាពក្រីក្រនិងកង្វះខាតការអប់រំ ការហូរចូលនូវវប្បធម៌ខ្លះ ដែលមិនល្អពីបរទេស ការប្រើប្រាស់នូវគ្រឿងញៀន និងភាពទន់ខ្សោយនៃការអនុវត្តច្បាប់ជាដើម ។

លោករតនា បានឱ្យដឹងថា បញ្ហានេះកើតមានឡើងដោយសារតែភាពល្ងង់ខ្លៅ ភាពក្រីក្រ និងភាពទន់ខ្សោយនៃច្បាប់ ។ លោកក៏បន្តថា ភាពអវិជ្ជានាំឱ្យជនល្មើសគ្មានការងារធ្វើ ទំនេរ ហើយធ្វើឱ្យគ្រួសារប្រឈមនឹងភាពក្រីក្រ ។ លុះដល់ពេលដែលគ្រួសារគាត់ក្រ គាត់នឹងមានគន្លាតដាច់ឆ្ងាយពីសង្គមខាងក្រៅ ។ តាមធម្មជាតិ ភាពទំនេរ នាំឱ្យមនុស្សមានចំណង់ផ្លូវភេទ ដល់ពេលដែលពួកគេចង់ គួបផ្សំនឹងភាពអវិជ្ជា និងកង្វះមធ្យោបាយផងនោះ ធ្វើឱ្យពួកគេអាចធ្វើអំពើដ៏លាមកទាំងនេះ ទៅដល់សាច់សាលោហិតពួកគេបាន ។ លោកថ្លែងថា : "តាមធម្ម-ជាតិ មនុស្សអាចបង្ហាញពីអំណាច និងចំណង់របស់ខ្លួន តែនៅលើអ្នកដែលទន់ខ្សោយប៉ុណ្ណោះ" ។

លោកស្រីរ័ត្នបានបញ្ជាក់ថា : "ផ្ទះតូចខ្វះខាត គេងមើលឃើញគ្នាទៅវិញទៅមកបូកនឹងគ្រឿងស្រវឹង និងការខ្វះការពិចារណា អាចឱ្យជនល្មើស ហ៊ានធ្វើអំពើអសីលធម៌ជាមួយកូនខ្លួនបាន" ។ លោកស្រី ក៏បន្តទៀតថា ក្រៅពីនេះក៏មានកត្តាមួយចំនួនទៀតអាចឱ្យជនរងគ្រោះមួយចំនួន ក្លាយជាជនរងគ្រោះដែរ នោះគឺភាពភ្លើតភ្លើន ការឆាប់ជឿទុកចិត្ត ការដែលឪពុកម្តាយទៅធ្វើការឆ្ងាយពីផ្ទះ និងយន្តការច្បាប់នៅទន់ខ្សោយ ។ លោកស្រីក៏បន្តថា ជួនកាលជនល្មើសប្រព្រឹត្តហើយ រត់បាត់ពីកន្លែងកើតហេតុគឺចប់ លើកលែងតែជនល្មើស ភ្លេចខ្លួនវិលមកកាន់កន្លែងកើតហេតុវិញទើបចាប់ ហើយខ្លះទៀតទាល់តែគ្រួសាររងគ្រោះតាមដាន ហើយរាយការណ៍ជូនសមត្ថកិច្ចដោយខ្លួនឯងទើបចាប់ជនល្មើសបាន ។

លោកវណ្ណៈបន្ថែម បញ្ហានេះកើតឡើង ដោយសារតែការហូរចូលនៃវប្បធម៌បរទេស និងការអនុវត្តន៍ច្បាប់នៅទន់ខ្សោយ ។ វីដេអូអាសអាភាស គេបានបញ្ចាំង ពាសវាលពាសកាល រីឯការបង្ក្រាបរបស់អាជ្ញាធរ គឺដូចជា សង្កត់ពពុះបាយ ។

**ផលប៉ះពាល់**

លោកស្រី វណ្ណាត ការធ្លាក់ចុះនៃសីលធម៌នេះគឺជាឧបសគ្គមួយនៃការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច នៅក្នុងប្រទេសកម្ពុជា ។ លោកស្រីបានអះអាងថា ការធ្វើឱ្យប្រទេសមួយមានការរីកចម្រើន ដូចជាយើងជិះកង់ដែរ ។ បើចង់ឱ្យកង់ទៅមុខដោយរលូននោះលុះត្រាតែកង់របស់វាទាំងពីរកុំឱ្យកង់ណាមួយ វាបែក បើកង់ណាមួយបែក គឺត្រូវប៉ះសិន ។ បើមិនដូច្នោះទេ គឺវាពិបាកទៅដល់គោលដៅណាស់ ។ លោកស្រីបន្តថា : "សេដ្ឋកិច្ចគឺជាកង់មួយ ចំណែកឯសីលធម៌គឺជាកង់មួយទៀត" ។ លោកស្រីបន្តថា កង់សេដ្ឋ-កិច្ចកំពុងតែទៅមុខហើយ តែកង់សីលធម៌កំពុងតែធូរ យើងត្រូវតែឈប់ប៉ះសិន ចាំទៅមុខទៀត" ។

លោករតនា លើកកម្ពស់ការអប់រំ លុបបំបាត់ភាពទំនេរ ជំរុញការបើកទូលាយឱកាស ទទួលការងារ និងលើកទឹកចិត្ត ឱ្យមានការចូលរួមក្នុងសកម្មភាពសង្គម លុបបំបាត់គម្លាតសង្គម ពង្រឹងប្រព័ន្ធច្បាប់ គឺជាដំណោះស្រាយដ៏មានប្រសិទ្ធភាព ។/

**កម្រិតនៃទោសឧក្រិដ្ឋ**

**លោកស្រីម៉ី ឧសភា មេធាវីប្រចាំនៅអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានឱ្យដឹងថា បើតាមផ្លូវច្បាប់ ករណីរំលោភចំពោះនីតិជន ជនល្មើសនឹងត្រូវផ្តន្ទាទោសពី១០ ទៅ១៥ឆ្នាំ ចំណែកអនីតិជនអាយុតិចជាង១៤ឆ្នាំនោះ ត្រូវប្រឈមមុខនឹងកាត់កាត់ទោសដាក់គុកពី១៥ ទៅ២០ឆ្នាំ និងសំណងជាប្រាក់។ ចំពោះករណីបៀតបៀនកេរ្តិ៍ភេទវិញ គឺអាចត្រូវកាត់ទោសដាក់គុកពី១ ទៅ៣ឆ្នាំ។**

**ជាទូទៅនៅក្នុងចំណោមជនជាប់ចោទទាំងអស់ដែលជនរងគ្រោះបានធ្វើការប្តឹងនោះ ជនល្មើសភាគច្រើន ដែលប្រព្រឹត្តអំពើរំលោភសេពសន្ថវៈច្រើនកាត់ទោសជាមធ្យម ១៧ឆ្នាំ។ រីឯការរំលោភលើនីតិជនវិញនោះ គឺត្រូវផ្តន្ទាទោស ១២ឆ្នាំ និងសំណងជាប្រាក់ចំនួន ១០លានរៀល ដោយមិនគិតថាអ្នកនោះជាសាច់ញាតិនឹងជនរងគ្រោះនោះឡើយ។**

August-2008.qxd 7/29/2008 10:17 AM Page 12

# កសិកម្ម

## ខ្យង ក៏អាចចិញ្ចឹមលក់បានដែរ

**ទស្សនាវដ្ដីកសិករ លេខ១០១**


Photo : L. Samphors

ខ្យងបឹងមានសារៈប្រយោជន៍ អាចធ្វើជាអាហារសម្រាប់មនុស្ស សត្វ ឬអាចយកធ្វើជីដាក់ដំណាំ។ ខ្យងបឹងគឺរស់ក្នុងទឹកសាប និងកន្លែងសម្បូរដោយសារធាតុរលួយ ឬមមោកភក់ (សារធាតុសរីរាង្គ) នៅបាតបឹង ស្រះ បឹងបួរ ប្រឡាយ ជ្រលង បៀ ឬត្រពាំង ។ល។ តាមធម្មជាតិ ខ្យងបឹងចាប់ផ្ដើមកូននារដូវភ្លៀងដើមឆ្នាំពីខែមិថុនាដល់ខែកក្កដា។ កូនទើបកើត បណ្តែតខ្លួនលើផ្ទៃទឹក បន្ទាប់មកវាតោងជាប់នឹងរុក្ខជាតិ ឬក៏មែកឈើដែលលិចក្នុងទឹក។

**លក្ខណៈសម្គាល់ខ្យងញីឈ្មោល**

ខ្យងញីមានព្រុយមាត់២ លាតសន្ធឹងទៅមុខ ពេលវារ។ ខ្យងឈ្មោលមានព្រុយមាត់នៅផ្នែកខាងស្ដាំ ហើយរមូលមកខាងឆ្វេងពេលវារ។ ខ្យងញីគឺភាគច្រើនធំជាងឈ្មោល និងវាមានទម្ងន់ពី៥០ ទៅ៨០ក្រាមក្នុង១ក្បាល (ខ្យងមេធ្វើពូជគួរតែមានអាយុពី១០ ទៅ ១២ខែ ឡើងទៅ)។

**ការចិញ្ចឹមខ្យង**

បើយើងចិញ្ចឹមខ្យងដោយដាក់កូន គឺត្រូវលែងកូនពី១០០-១៥០ក្បាល ក្នុងផ្ទៃទឹក១$ម^2$ បើលែងមេពូជ គឺ១៥-២០ខ្យង ក្នុង ១$ម^2$ (គឺលែងយ៉ាងណាឱ្យមានមេមួយ និងឈ្មោលមួយ) និងមុនពេលលែងកូនខ្យងទៅក្នុងស្រះ យើងត្រូវបង្កើតចំណី ជាមុនដោយចិញ្ច្រាំចំបើង ឬក៏ដើមចេកហាលស្ងួត លាយជាមួយអាចម៍ក្របី មាន់ ជ្រូក ដាក់ រាយពេញបាតស្រះ ឬប្រឡាយ ពី១-២គក ក្នុង ១$ម^2$ នៃផ្ទៃស្រះ ឬប្រឡាយ រួចហើយទុករយៈពេល ១០ថ្ងៃ គឺទាល់តែឃើញមានពពុះនៅលើផ្ទៃទឹក ទើបលែងខ្យង។ ក្រៅពីចំណីនេះ យើងក៏ត្រូវផ្ដល់ចំណីបន្ថែមដូចជាកន្ទក់ ម្សៅពោត ម្សៅដំឡូង ស្លឹកដំឡូងជ្វា ត្រកួន (ហាន់បុកឱ្យម៉ដ្ឋ) ដាក់នៅកន្លែងទឹករាក់ និងមួយថ្ងៃឱ្យចំណីស៊ី មួយដង។ ស្រះ ឬក៏ប្រឡាយគួរមានទំហំពី ១០០$ម^2$ ទៅ៣០០$ម^2$ ដែលនៅក្នុងនោះកន្លែងជ្រៅ គឺគួរមានជម្រៅពី ៥តឹក ទៅ៨តឹក និងកន្លែងរាក់ពី ២តឹក ទៅ៣តឹក។ យើងដាំត្រកួនទឹកធ្វើជាជម្រក លើផ្ទៃស្រះ ឬប្រឡាយ ដើម្បីឱ្យខ្យងតោង និងចាប់ចំណីស៊ី។ កន្លែងចិញ្ចឹម ត្រូវមានម្លប់ខ្លះ ហើយធ្វើរបាំងព្រួល ឬសំណាញ់ស្បៃមុង ព័ទ្ធជុំវិញស្រះ ព្រោះខ្យងអាចវារចេញទៅកន្លែងថ្មី និងដើម្បីការពារសត្វស៊ីដូចជា កណ្ដុរ បក្សី ឆ្មា ឬឆ្កែ។ យើងក៏ត្រូវការពារកុំឱ្យមានសារធាតុពុលហូរ ចូលស្រះ ឬប្រឡាយចិញ្ចឹមខ្យង។ បើចិញ្ចឹមបាន ៤ខែ អាចបានទម្ងន់ ២០-៤០ក្រាមក្នុងមួយកូនខ្យង៕

## បរិស្ថាន

### សន្សំថាមពល

ដើម្បីដោះស្រាយនូវបញ្ហាផែនដីឡើងកម្ដៅ ដែលបង្កជាគ្រោះមហន្តរាយផ្សេងៗ មនុស្សអាចចូលរួមជាសកម្មភាព ដូចជា សន្សំថាមពល (អគ្គិសនី


Photo : geres

អុស...) ដាំដើមឈើ ផ្សព្វផ្សាយពីបញ្ហានេះទៅអ្នកដទៃ សន្សំសំចៃទឹក ប្រើប្រាស់សម្ភារៈ កែច្នៃ ឬក៏ប្រើប្រាស់ថាមពលកកើតឡើងវិញ (ថាមពលព្រះអាទិត្យ ខ្យល់ វារី អគ្គិសនី...) -ល-។ ក្នុងការចូលរួមជំរុញសកម្មភាពទាំងនេះ អង្គការ geres នៅកម្ពុជាដែលគោលដៅគឺចូលរួមការពារបរិស្ថាន ឬលើកកម្ពស់ជីវភាពប្រជាជនតាមរយៈបច្ចេកវិទ្យាស្អាត សមស្រប និងតម្លៃថោកសមរម្យ បានបង្កើតនូវចង្ក្រានថ្មីជាច្រើនប្រភេទ ដែលមានគោលការណ៍សន្សំសំចៃអុស-ធ្យូង ក្នុងនោះមានចង្ក្រានឡូវថ្មី និងចង្ក្រាននាងកង្រី ដែលអាចឱ្យប្រជាជនប្រើប្រាស់ អាចកាត់បន្ថយអុស-ធ្យូងបានពី២៥% ទៅ៣៥% តិចជាងចង្ក្រានបុរាណ។ ចំពោះចង្ក្រានទាំងពីរប្រភេទនេះ អង្គការ Geres ជាអ្នកផ្ដល់បច្ចេកទេស ឱ្យអ្នកផលិតលក់ តែអ្នកផលិតត្រូវតែគោរពតាមបទដ្ឋានបច្ចេកទេសរបស់អង្គការឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ។ ចង្ក្រានឡូវថ្មីមានរយៈពេល ប្រើប្រាស់បីឆ្នាំ និងមានលក់នៅទីផ្សារនានា ដែលគេលក់ក្នុងតម្លៃពី១៣០០០រៀល ទៅ១៧០០០រៀល។ ចំណែកឯចង្ក្រាននាងកង្រីមានរយៈពេលប្រើប្រាស់ជាមធ្យម ១ឆ្នាំ តែបើថែទាំបានល្អ អាចបានពី១ឆ្នាំ កន្លះទៅ ២ឆ្នាំ។ ចង្ក្រាននេះច្រើនមានលក់នៅបណ្ដាលទីផ្សារ ខេត្តកំពង់ឆ្នាំង តម្លៃប្រហែល៣០០០រៀល និងទីផ្សារក្នុងរាជធានីភ្នំពេញ និងតាមរទេះគោលក់ក្នុងតម្លៃពី៥០០០រៀល ទៅ៦០០០រៀល៕ **ផាត សំភី**



# សុខភាព

## មហារីកចុងពោះវៀនធំច្រឡំនឹងឫសដូងបាត

**ផាត សំភី**

បើតាមប្រសាសន៍របស់លោកវេជ្ជបណ្ឌិតឡឹម តារា ឯកទេសវះកាត់ទូទៅ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត (ពេទ្យរុស្ស៊ី) បានឱ្យដឹងថា:

ជំងឺមហារីក ផ្នែកខាងចុងពោះវៀនធំ និងជំងឺឫសដូងបាត គឺមានរោគសញ្ញាប្រហាក់ប្រហែលគ្នា នៅដំណាក់ដំបូង ដូចជាមានឈាមប្រឡាក់លាមកនៅពេលបន្ទោរបង់ និងក្រោយបន្ទោរបង់ហើយ មានឈាមស្រស់តក់ៗ ជាដើម។ ដោយហេតុនេះហើយនៅពេលអ្នកជំងឺមហារីកចុងពោះវៀនធំដែលមកកាន់មន្ទីរពេទ្យជំនាញ និងជួបវេជ្ជបណ្ឌិតឯកទេស គឺស្ថានភាពជំងឺ ស្ថិតនៅក្នុងស្ថានភាពធ្ងន់ធ្ងរណាស់ទៅហើយ ពីព្រោះគាត់ច្រឡំព្យាបាលជំងឺមហារីកចុងពោះវៀនធំតាមរបៀបជំងឺឫសដូងបាតជាមួយនិងគ្រូពេទ្យបុរាណខ្មែរ គ្រូចិនសែ ឬវេជ្ជបណ្ឌិតខ្លះដែលពិនិត្យជំងឺសើៗ គ្រាន់តែសួរនាំ រួចឱ្យថ្នាំ។

លោកវេជ្ជបណ្ឌិតឡឹម តារា សង្កត់ធ្ងន់ដែរថា: "បើមានរោគសញ្ញាគួរឱ្យសង្ស័យដូចបានរៀបរាប់ខាងលើ អ្នកជំងឺត្រូវស្វែងរកវេជ្ជបណ្ឌិតជំនាញឯកទេសពិតប្រាកដ ដែលធ្វើការពិនិត្យផ្ទាល់ ក្រៅពីការសួរនាំដូចជាមានឧបករណ៍បើកក្រសាលគូទមើល ប្រើម្រាមដៃលូកត្រួតពិនិត្យដើម្បីឱ្យដឹងថា តើនោះជាដុំសាច់មហារីក ឬក៏គ្រាន់តែជំងឺឫសដូងបាតធម្មតា រួចព្យាបាលតាមបច្ចេកទេសឱ្យបានត្រឹមត្រូវ"។

ចំពោះជំងឺឫសដូងបាត វាមិនធ្ងន់ធ្ងរគ្រោះថ្នាក់ដល់អាយុជីវិតនោះទេ បើមានការព្យាបាលត្រឹមត្រូវ។ ប៉ុន្តែសម្រាប់ជំងឺមហារីកចុងពោះវៀនធំ ការស្វែងរកវេជ្ជបណ្ឌិតឯកទេសដើម្បីពិនិត្យ ព្យាបាលជំងឺ ពីរោគសញ្ញាដំបូង មានសារសំខាន់ខ្លាំងណាស់ ព្រោះជំងឺមហារីកចុងពោះវៀនធំនៅក្នុងដំណាក់កាលទីមួយ គេអាចមានសង្ឃឹមព្យាបាលដាច់បានច្រើន ឬបើវាមិនជាដាច់ទេ ១០០%នោះទេ អ្នកជំងឺក៏អាចរស់បានយូរឆ្នាំទៅមុខទៀតដែរ។


Photo : P. Samphy

ជំងឺមហារីកចុងពោះវៀនធំនេះអាចបណ្ដាលមកពីច្រើនមូលហេតុណាស់ តែមូលហេតុដែលគួរឱ្យកត់សម្គាល់គឺជំងឺបណ្ដាលមកពីកត្តាតំណពូជ ដែលអ្នកជំងឺ អាចមានជីដូនជីតា ជីដូងជីតាទួតធ្លាប់មានជំងឺនេះ ឬក្រៅពីនេះ ជំងឺមហារីកខាងចុងពោះវៀនធំអាចបណ្ដាលមកពីការប៉ះពាល់ពីវីរុស ឬក៏ជាតិគីមីខ្លះ ដែលធ្វើឱ្យប្រែប្រួលសែននៅកន្លែងនោះ។

ជំងឺមហារីកខាងចុងពោះវៀនធំ គឺច្រើនកើតឡើងនៅលើមនុស្សចាស់ ប៉ុន្ដែបើជួន វាកើតមាននៅលើមនុស្សវ័យក្មេង គឺមហារីកនេះ កាន់តែសាហាវ ៕

### មួយឆ្នាំៗ ស្លាប់ស្ត្រីជាម្ដាយ ២០០០ នាក់

គេបានធ្វើការប៉ាន់ប្រម៉ាណថា ជារៀងរាល់ឆ្នាំ មានស្ត្រីកម្ពុជាប្រមាណជា ២០០០នាក់ បានស្លាប់នៅក្នុងពេលដែលពួកគាត់មានផ្ទៃពោះ និងពេលសម្រាលកូន។

យោងទៅតាមស្ថិតិសុខភាពជាតិនាឆ្នាំ២០០៧ នៃក្រសួងសុខាភិបាលបានឱ្យដឹងថា មូលហេតុនៃការស្លាប់នេះដ៏ខ្ពស់នេះ គឺដោយសារ តែបញ្ហាដ៏ធំចម្បងមួយ គឺកង្វះខាតនូវឆ្មបជំនាញដែលទទួលការបណ្ដុះបណ្ដាលត្រឹមត្រូវ និងកង្វះការយល់ដឹងពីគ្រោះថ្នាក់របស់ស្ត្រីជាមាតា។ ស្ថិតិកាលពីឆ្នាំ២០០៧ កន្លងទៅនេះ បានឱ្យដឹងថា កម្ពុជាមានឆ្មបដែលទទួលការបណ្ដុះបណ្ដាល ត្រឹមតែចំនួន ៣១៨៤នាក់ប៉ុណ្ណោះ ដោយនៅក្នុងនោះ មាន១៣៣៩នាក់ គឺជាឆ្មបកម្រិតបឋម និង១៨៤៥នាក់ ជាឆ្មបកម្រិតមធ្យម។ នៅក្នុងចំណោមមណ្ឌលសុខភាពជិត ៩០០កន្លែងនៅក្នុងប្រទេសនោះ មានជាង ១០០កន្លែង ហើយដែលមិនទាន់មានឆ្មប។

### ជំងឺគ្រុនចាញ់កំពុងរាតត្បាតនៅប៉ៃលិន


Photo: DR

នៅក្នុងចំណោមជំងឺឆ្លងនានា ជំងឺគ្រុនចាញ់នៅតែជាជំងឺមួយដែលមានការរីករាលដាលច្រើនជាងគេសម្រាប់អ្នករស់នៅក្នុងទីក្រុងប៉ៃលិនដែលស្ថិតនៅភាគពាយព្យនៃប្រទេសកម្ពុជា។

លោកហាក់ សៀប ជាអនុប្រធានមណ្ឌលសុខភាពអូរច្រាក្រុងប៉ៃលិនបានមានប្រសាសន៍ថា ជំងឺដែលបណ្ដាលឱ្យអ្នកស្រុកមកកាន់មណ្ឌលសុខភាពច្រើនជាងគេនោះ មានដូចជា ជំងឺគ្រុនចាញ់ រាក ជំងឺផ្លូវដង្ហើម និងជំងឺរបេង-ល-។

លោកបានបញ្ជាក់ថា: "ក្នុងមួយថ្ងៃៗ មានអ្នកជំងឺជាមធ្យមប្រមាណជាង២០នាក់ មករកសេវាថែទាំសុខភាព"។ លោកបានបន្តទៀតថា ដោយសារតែភូមិសាស្ត្រ ទីក្រុងប៉ៃលិន សម្បូរព្រៃឈើនោះ វាក៏ក្លាយជាជម្រកមូសដែកគោលដ៏ធំ ហើយកាលពីឆ្នាំ២០០៧ កន្លងទៅ មណ្ឌលសុខភាពអូរច្រា បានទទួលអ្នកជំងឺគ្រុនចាញ់នេះចំនួន ៨៩៧៩នាក់ ប៉ុន្តែដោយសារតែកិច្ចខិតខំប្រឹងប្រែងអប់រំ និងកម្មវិធីបង្ការនិងការពារជំងឺនេះ នាដើមឆ្នាំ២០០៨ ស្ថានភាពនៃជំងឺហាក់ដូចជាមានការធ្លាក់ចុះបន្តិច។

លោកបានបន្តថា ក្រុងកំពុងយកចិត្តទុកដាក់អប់រំឱ្យពលរដ្ឋ ឱ្យប្រើមុងជ្រលក់ថ្នាំ និងកម្មវិធីផ្សេងៗទៀតដើម្បីបង្ការមូស។ ហេតុនេះយើងរំពឹងថា តួលេខនៃជំងឺនឹងធ្លាក់ចុះ ២៥% ក្នុងឆ្នាំ២០០៨នេះ។

នៅក្នុងប្រទេសកម្ពុជា ខេត្តដែលរងគ្រោះដ៏ធ្ងន់ធ្ងរដោយសារតែជំងឺគ្រុនចាញ់ មានដូចជា ព្រះវិហារ សៀមរាប ឧត្ដរមានជ័យ បន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន កោះកុង និងពោធិ៍សាត់។

តួលេខពីមជ្ឈមណ្ឌលជាតិកំចាត់ជំងឺគ្រុនចាញ់បានឱ្យដឹងដែរថា កាលពីឆ្នាំ២០០៧កន្លងទៅ ជំងឺគ្រុនចាញ់ កើតមានចំពោះមនុស្សទូទាំងប្រទេស ចំនួន ៥៩៨៤៨នាក់។ ហើយនាដើមឆ្នាំកន្លងទៅនេះ វាក៏បានកើតមានលើមនុស្សចំនួន ១៥៥៤២នាក់៕

**ខាន់ ភិរម្យ**

August-2008.qxd 7/29/2008 10:17 AM Page 14





Photo : K. Phirum

# កំពូលយុទ្ធគុណបុរាណខ្មែរហៅក្បាច់គុណ ខម

**ខាន់ ភិរម្យ**

ផ្ទាំងចម្លាក់ពីក្បាច់ប្រយុទ្ធទាំងឡាយ ដែលគេឃើញមានឆ្លាក់ជាប់ នៅតាមជញ្ជាំងនៃប្រាសាទអង្គរដ៏ល្បីល្បាញនៅទូទាំងសកលលោករបស់ប្រទេសកម្ពុជា បានសបញ្ជាក់ឱ្យឃើញពីផ្នែកមួយ នៅក្នុងគម្ពីរយុទ្ធគុណបុរាណខ្មែរផងដែរ។

លោកចាន់ ប៊ុនធឿន អាយុ៥៧ឆ្នាំ ដែលជាគ្រូយុទ្ធគុណបុរាណខ្មែរ ប្រចាំនៅសំណាក់យុទ្ធគុណ ខម បានមានប្រសាសន៍ថា ក្រៅតែពីប្រាសាទបុរាណ ដែលជាសក្ខីភាពមួយបង្ហាញអំពីភាពសម្បូរបែបបទនៃវប្បធម៌របស់ខ្លួននោះ ខ្មែរយើងក៏មាននូវភស្តុតាងជាច្រើនទៀតដែលបញ្ជាក់អំពីអរិយធម៌ ដ៏រុងរឿងរបស់ខ្លួន នៅក្នុងនោះក៏មានដូចជាយុទ្ធគុណខ្មែរមួយផងដែរ។

លោកបានបន្តទៀតថា : "សាសន៍គេ មានយុទ្ធគុណរបស់គេ តែយើងក៏មានយុទ្ធគុណផ្ទាល់របស់យើងដែរ កុំយល់ច្រឡំថា យើងអត់មាន។ បើយើងគ្មានយុទ្ធគុណ ផ្ទាល់ខ្លួននោះ ពុំមែនជាតិសាសន៍យើងកាលពីជំនាន់អតីតកាល គឺជាប្រទេសដែលមានឫទ្ធានុភាពដ៏ខ្លាំងក្លានៅក្នុងតំបន់នោះឡើយ"។

លោកបន្ថែមថា តាមរយៈគម្ពីរដែលដូនតារបស់លោកបន្សល់ទុកនោះ យុទ្ធគុណខ្មែរមានចំនួន ១៣ទ្វារ ហើយក្នុងទ្វារនីមួយៗ គេអាចយកទៅបំបែកចេញ ជាសាច់ស្មៀតរាប់រយ ដើម្បីធ្វើការប្រយុទ្ធ ដែលអាចធ្វើឱ្យសត្រូវគេខ្លបខ្លាចយើងបាន។ យុទ្ធគុណទាំងនេះ ត្រូវបានបុព្វបុរសរបស់ខ្មែរ យើងរកឃើញតាំងតែពីសតវត្សរ៍ទី១២ មកម្ល៉េះ ហើយនៅក្នុងអំឡុងពេលនោះ ក៏ជាសម័យដែលខ្មែរសម្បូររុងរឿងផងដែរ។

លោកក៏បានបន្តទៀតថា គម្ពីរដែលលោកមានសព្វថ្ងៃនេះ គឺជាគម្ពីរចម្លងមួយ ចេញមកអំពីគម្ពីរយុទ្ធគុណបុរាណខ្មែរ ដែលត្រូវចងក្រង ដោយព្រះបាទអង្គច័ន្ទរាជា ដែលជាអតីតព្រះមហាក្សត្រ១អង្គ សោយរាជ្យនៅកម្ពុជាសម័យលង្វែក។

លោកបានឱ្យដឹងថា ដើម្បីរៀនឱ្យចេះទាំង ១៣ទ្វារនេះ គេអាចចំណាយជាពេលវេលារាប់សិបឆ្នាំ ជាក់ស្តែងសម្រាប់លោក បានរៀនតាំងតែពីអាយុ ៧ឆ្នាំ ហើយរហូតមកដល់ពេលនេះ គឺទើបតែចេះបានបួនទ្វារ តែប៉ុណ្ណោះសម្រាប់ប្រើការនោះ៕

## អំណាន

### រស្មីឥន្ទធនូ



គឺជាស្នាដៃមួយ ក្នុងចំណោមស្នាដៃជាច្រើនរបស់អ្នកស្រី ម៉ៅ សំណាង ដែលជាអ្នកនិពន្ធ ប្រលោមលោកពោរពេញដោយបទពិសោធន៍ម្នាក់នៅក្នុងយុគសម័យបច្ចុប្បន្ន។

រឿងនេះជាប្រលោមលោកបែបមនោសញ្ចេតនាផង និងក៏ជាប្រភេទរឿងបែបស៊ើបអង្កេតផង។ ការចាប់ផ្តើមនៃរឿងនេះមានចំណុចមួយចំនួនគួរឱ្យចាប់អារម្មណ៍។ ពេលចាប់អានរឿងនេះ យើងនឹងមានចម្ងល់ជាច្រើនចោទសួរខ្លួនឯង ជាពិសេសចង់ដឹងថា "តើនៅទីបញ្ចប់ការតាំងចិត្តកែប្រែខ្លួនជាថ្មីរបស់អតីតក្រុមចោរសមុទ្រក្រោមការដឹកនាំរបស់ឥន្ទធនូនឹងទទួលបានលទ្ធផលយ៉ាងដូចម្តេច ?"

នៅក្នុងផ្ទៃរឿងនេះ ក៏មានបង្កប់នូវចំណោទបញ្ហាជាច្រើន ដែលតួអង្គសំខាន់ៗត្រូវប្រឈមមុខ និងដោះស្រាយ។ តួអង្គនីមួយៗ មានលក្ខណៈពិសេសរៀងៗខ្លួន ហើយពួកគេត្រូវស្វែងយល់ពីគ្នាជាច្រើន មុននឹងកំណត់បានថា អ្នកណាជាមិត្ត? និងអ្នកណាជាសត្រូវ?។

រឿងប្រលោមលោកនេះមានកម្រាស់ ១៨៧ទំព័រ និងត្រូវបានដាក់លក់ក្នុងតម្លៃប្រហែល ៥០០០រៀល។

### បុប្ផាបាត់ដំបង



គឺជាកម្រងរឿងមនោសញ្ចេតនាអមដោយរូបភាពគ្រប់ទំព័រ ដែលជាស្នាដៃពោរពេញដោយទេពកោសល្យរបស់លោកឯម សត្យា។ រឿងនេះរៀបរៀងឡើងជាឆាករូបភាពដែលបង្កលក្ខណៈងាយស្រួលសម្រាប់អ្នកអាន។ ថ្វីត្បិតសាច់រឿង មានលក្ខណៈសាមញ្ញបន្តិចក៏ដោយ ក៏ជាខ្សែរឿងគួរឱ្យចង់តាមដាន ហើយក៏មានតម្លៃសម្រាប់ឱ្យអ្នកអានយកទៅត្រិះរិះពិចារណាផងដែរ។ សុត្ថា ដែលជាតួអង្គឯកនៅក្នុងរឿងនេះ ត្រូវជួបប្រទះនឹងរឿងសៅហ្មងជាច្រើន ពីព្រោះតែផល្លាជាទីស្រលាញ់មិនព្រមស្តាប់ការពន្យល់បកស្រាយរបស់លោក។ នៅក្នុងជីវិតពិត ក៏ដូច្នេះដែរ ជួនកាលពីព្រោះតែស្រលាញ់ ទើបបានជាអន់ចិត្តខ្លាំងរហូតអត់ឱនឱ្យមិនបាន នៅពេលលេចឮ ឬមើលឃើញថាមនុស្សដែលខ្លួនស្រលាញ់ ប្រព្រឹត្តអំពើមិនគប្បី។

រឿងបុប្ផាបាត់ដំបង ក៏មានបង្កប់នូវឈុតឆាកកំប្លុកកំប្លែងគួរឱ្យចូលចិត្តផងដែរក្នុងដំណើររឿងពីដើមដល់ចប់។

រឿងនេះត្រូវបានដាក់លក់ក្នុងមួយក្បាល ដែលមានតម្លៃ ៤០០០ រៀល និងមានកម្រាស់ ១០០ទំព័រ។

**ម៉េង សុមនា**





# "លឿនបំផុត ខ្ពស់បំផុត ខ្លាំងបំផុត..." ជាបាវចនាជីវិត

**អាន ឡូរ៉ី ប៉ូរ៉េ**



Photo : DR

កីឡាអូឡាំពិករាប់បញ្ចូលក្នុងចំណោមការប្រកួតកីឡាដ៏រស់រវើកបំផុតនៅលើពិភពលោក។ វាត្រូវបានបែងចែក ជាកីឡាអូឡាំពិករដូវរងារ និងកីឡាអូឡាំពិករដូវក្តៅ។ វិញ្ញាសានានាបានប្រមូលផ្តុំនូវកីឡាកររាប់ពាន់នាក់ ជារៀងរាល់បួនឆ្នាំម្តង តាំងពីឆ្នាំ១៨៩៦! តែប្រភពនៃវិញ្ញាសាកីឡានេះមានតាំងពីសម័យបុរាណមកម្ល៉េះ។ គេបានរកឃើញនូវដានកីឡានេះតាំងពីសតវត្សរ៍ទី៨ មុនគ្រិស្តសករាជនៅប្រទេសក្រិកដែលជាកន្លែងវាចាប់កំណើត។

សម័យនោះ ការប្រកួតកីឡាគឺទុកបម្រុងសម្រាប់បុរស ដែលប្រឈមមុខគ្នា តាមរយៈការប្រណាំងរទេះសេះដែលអូសដោយសេះ ២ក្បាល ឬ៤ក្បាល ការរត់ប្រណាំង ការចោលចានឬចោលលំពែង ការលោតចម្ងាយ និងកីឡាបោកចំបាប់។ អ្នកឈ្នះត្រូវបានគេបំពាក់មកុដដែលមានដោតមែកអូលីវ។

ចំណែកឯការប្រគល់មេដាយ ដូចជា មេដាយសំរឹទ្ធ មេដាយប្រាក់ និងមេដាយមាស សម្រាប់អ្នកឈ្នះពីលេខមួយដល់លេខបី ត្រូវបានគេប្រគល់ជូនអ្នកឈ្នះចាប់ តាំងពីកីឡានេះចាប់កំណើតសាជាថ្មី នាដំណាច់សតវត្សរ៍ទី១៩មក។ នេះដោយសារកីឡាអូឡាំពិកបានរលត់បាត់ទៅម្តងហើយ នាពេលដែលអរិយធម៌ក្រិក ស្ថិតនៅក្រោមការគ្រប់គ្រង របស់ជនជាតិរ៉ូម៉ាំង។ វាបានរលត់បាត់ម្តង នៅឆ្នាំ៣៩៣ ដោយសារតែមានការហាមឃាត់ពីព្រះចៅអធិរាជរ៉ូម៉ាំង ថេអូដូស៍ទីមួយ (Théodose Ier) ដែលបានវិនិច្ឆ័យថា កីឡានេះឧទ្ទិសដល់អាទិទេព ច្រើនអង្គដែលផ្ទុយពីគ្រិស្តសាសនា ដែលត្រូវបង្ខំឱ្យប្រតិបត្តិនៅក្នុងចក្រភព។

មានជនជាតិបារាំងម្នាក់ គឺលោក ព្យែរ៍ ដឺ គូបឺតាំង (Pierre de Coubertin) ដែលប្រោសកីឡានេះឱ្យរស់ឡើងវិញ អំឡុងពេលដែលក្រុមអ្នកបុរាណវិទូរបស់លោកបានស្វែងរកឃើញដាននៅតំបន់អូឡាំពី(Olympie) ដែលជាឈ្មោះស្ថានីយកំណាយបុរាណវិទ្យា។ ហើយនេះជាប្រភពនៃឈ្មោះរបស់កីឡាអូឡាំពិក។ លោកព្យែរ៍ជាអ្នកបង្រៀនកីឡានេះដល់ប្រជាជនទាំងអស់ ហើយផ្សព្វផ្សាយកីឡាអូឡាំពិកដោយបើកចំហសម្រាប់មនុស្សគ្រប់ឋានៈនៅក្នុងសង្គម ដោយបំពាក់ឱ្យពួកគេនូវបាវចនា ១ ថា : "លឿនបំផុត ខ្ពស់បំផុត ខ្លាំងបំផុត..." ដោយតម្រាប់តាមមិត្តភក្តិរបស់គាត់ គឺអាបេ ហង់រី ឌីដុង (l'abbé Henri Didon) ដែលធ្លាប់បានបង្រៀននូវគុរុកោសល្យសម្រាប់លេងកីឡាអូឡាំពិក។ លោកព្យែរ៍ដឺ គូបឺតាំង រចនាដោយខ្លួនលោកនូវទង់សញ្ញារបស់កីឡាអូឡាំពិក ដែលផ្សំឡើងដោយកងទាំងប្រាំប្រទាក់គ្នា។ ប៉ុន្តែភ្លើងគុបអូឡាំពិកគឺទើបចាប់កំណើតឡើងនៅឆ្នាំ១៩២៨ ប៉ុណ្ណោះ ដែលវាគឺជាតំណាងឱ្យទំនាក់ទំនងរវាងប្រទេសក្រិកបុរាណនិងកីឡាសម័យទំនើប។ ការរត់ភ្លើងគប់ទៅរកកន្លែងប្រារព្ធពិធី ជាគំនិតថ្មីដែលបំផុសដោយក្រុមណាស៊ីអ៊ីត្លែរនៅឆ្នាំ១៩៣៦។ ចំណែកឯរូបសញ្ញាតុក្កតាអូឡាំពិកត្រូវបានបង្កើតឡើង នៅឆ្នាំ១៩៦៨។

ប្រទេសទាំងឡាយណា ដែលទទួលកីឡាអូឡាំពិកបញ្ហាមិនមែនសាមញ្ញគ្រាន់តែជានិមិត្តរូប ឬក៏ការលេងកីឡាប៉ុណ្ណោះទេ។ សម្រាប់ប្រទេសម្ចាស់ផ្ទះរៀបចំកីឡាអូឡាំពិក គឺត្រូវធានាឱ្យប្រាកដនូវការរៀបចំ និងការសាងសង់ ដែលនេះជាការបង្កើតឱ្យមានការងារ និងសកម្មភាពជាច្រើន។ ឥទ្ធិពលទៅលើសេដ្ឋកិច្ច ទេសចរណ៍ ពីការជួបជុំមនុស្សម្នា គឺធំសម្បើមណាស់។ ដូច្នេះគ្រប់ទីក្រុងចង់ប្រារព្ធរៀបចំកីឡាអូឡាំពិកនេះណាស់។ បន្ទាប់ពីក្រុងប៉េកាំងប្រទេសចិន គឺទីក្រុងឡុងដ៍ប្រទេសអង់គ្លេសដែលនឹងរៀបចំកីឡាអូឡាំពិករដូវក្តៅ ឆ្នាំ២០១២។

### តើកីឡាអូឡាំពិក នឹងត្រូវបានគេធ្វើពហិការឬ?

Photo : DR

ជាច្រើនខែមកហើយ បស្ចិមប្រទេសជាច្រើនបានធ្វើសង្គ្រាមស្លាបប៉ាកាអំពីសារៈសំខាន់នៃការធ្វើពហិការចំពោះពិធីបើកការប្រកួតកីឡាអូឡាំពិកនៅទីក្រុងប៉េកាំង ដើម្បីតវ៉ាប្រឆាំងនឹងការមិនគោរពសិទ្ធិមនុស្សក្នុងប្រទេសចិន។

ការតវ៉ាប្រឆាំង និងការមិនយល់ព្រមខាងនយោបាយនេះមិនមែនជារឿងថ្មីទេនៅក្នុងប្រវត្តិសាស្ត្រនៃកីឡាអូឡាំពិកនេះ។ នៅឆ្នាំ១៩៥៦ ប្រទេសអឺរ៉ុបបានបដិសេធមិនចូលរួមដើម្បីប្រឆាំងចំពោះការបង្ក្រាបរបស់សូវៀតនៅក្នុងប្រទេសហុងគ្រី។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ប្រទេសអាហ្វ្រិកបានធ្វើពហិការដូចគ្នានេះ ដើម្បីប្រឆាំងការរើសអើងជាតិសាសន៍នៅប្រទេសអាហ្វ្រិកខាងត្បូង។ នៅឆ្នាំ១៩៨០ សហរដ្ឋអាមេរិក និងគណៈប្រតិភូ ៦៤ប្រទេស ទៀត បានតវ៉ាប្រឆាំងតាមរយៈការមិនចូលរួមកីឡាអូឡាំពិកដើម្បីប្រឆាំងនឹងអន្តរាគមន៍របស់សូវៀតនៅក្នុងប្រទេសអាហ្គានីស្ថាន។

August-2008.qxd 7/29/2008 10:17 AM Page 16

## ល្បែងកំសាន្ត

**រាប់សត្វ**

*ករុណា និងវិសាខាកំពុងរាប់សត្វៗ ប្អូនសាកជួយរាប់ផងទៅមើល!*
*តើមានសត្វជើងបួនប៉ុន្មាននៅទីនេះ?*



សូមថ្លែងអំណរគុណដល់អង្គការស៊ីប៉ាដែលជួយឧបត្ថម្ភទំព័រនេះ។
អង្គការស៊ីប៉ា : ប្រអប់សំបុត្រ ៣១ ផ្ទះលេខ៩ ផ្លូវ២១ រាជធានីភ្នំពេញ-កម្ពុជា ឬទូរស័ព្ទ : ០២៣ ២១៦ ០០១។

# សេចក្ដីជូនដំណឹង!

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក នឹងមានរៀបចំការប្រឡងប្រជែងខាងគូរគំនូរ លើប្រធានបទអំពី "សិទ្ធិកុមារ"។

លក្ខខណ្ឌចូលរួមប្រឡង : កុមារគ្រប់ៗរូប ដែលមានអាយុពី ៨ឆ្នាំ ទៅដល់១៦ឆ្នាំ។

សូមប្អូនៗផ្ញើគំនូរមកកាន់អាសយដ្ឋានការិយាល័យយើង ឬតាមរយៈលោកឪពុក ឬបងស្រីដែលនៅជិតបំផុត ឱ្យបានមុនថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ ខាងមុខនេះ។

## ការងារប្រចាំខែ

- ថ្ងៃទី១១-១៥ កក្កដា និង២៥-២៩ កក្កដា និង៨-១២កញ្ញា : សិក្ខាសាលាការ៉ូ និងសេដ្ឋា នៅព្រះសហគមន៍ខេត្តកំពង់ចាម។
- ចាប់ពីថ្ងៃទី១៩ កក្កដា និងរៀងរាល់ថ្ងៃអាទិត្យ : ការសម្ដែងរឿងជាប្រវត្តិរបស់លោកប៉ូលនៅព្រះសហគមន៍ក្រុងកំពង់សោម។
- ថ្ងៃទី២៧ កក្កដា : ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនីតិកាលទីបួន។
- ថ្ងៃទី២៧ កក្កដា : ជំហានទីមួយសម្រាប់អ្នកស្វែងយល់នៅព្រះសហគមន៍អ្នកលឿង។
- ថ្ងៃទី២៨ កក្កដា ដល់១៥ សីហា : ក្រុមស្ម័គ្រចិត្តជនជាតិអេស្ប៉ាញមកទស្សនកិច្ច និងសួរសុខទុក្ខក្មេងកំព្រា និងក្រុមសួនសុវណ្ណកុមារ។
- ថ្ងៃទី៣០ កក្កដា- ទី១ សីហា : សិក្ខាសាលាពីការផលិតកម្មវិធីវិទ្យុនៅសៀមរាបរៀបចំដោយមណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក។
- ដើមខែសីហាខាងមុខនេះ : ព្រះសហគមន៍ក្រុងព្រះសីហនុនឹងចាប់ផ្ដើមសាងសង់ព្រះវិហារថ្មីនៅបឹងតាព្រហ្មបិតនៅ ២៥គមពីក្រុង។
- ថ្ងៃទី១១-១៣ សីហា : ការប្រជុំស្ដីពីការណែនាំផ្លូវវិញ្ញាណរៀបចំដោយកញ្ញាស្រីមុិច លោកបូជាចារ្យ ហ្វ្រង់កូ និងបងស្រីផនធិប នៅខេត្តកំពង់ធំ។
- ថ្ងៃទី១១-១៥ សីហា : សិក្ខាសាលានៅព្រះសហគមន៍ខេត្តបាត់ដំបង រៀបចំដោយមណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក។
- ថ្ងៃទី២២-២៤ សីហា : មហាសន្និបាត The witness of the holy spirit ធ្វើនៅកំពង់ចាម ដែលមានអ្នកចូលរួម ២០០នាក់។
- ថ្ងៃទី២៦-៣០ សីហា : សន្និបាតយុវជននៅព្រះសហគមន៍ខេត្តសៀមរាប។
- ថ្ងៃទី៣១ សីហា : ជំហានទី១ នៅព្រះសហគមន៍ខេត្តកំពត ចំនួន ៣៦នាក់។


## សូមផ្សាយពាណិជ្ជកម្ម

គ្រប់អង្គការ ក្រុមហ៊ុន និងស្ថាប័នទាំងឡាយណាដែលមានបំណងចង់ផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ ឬផ្សាយដំណឹងជ្រើសរើសបុគ្គលិក ក្នុងតម្លៃទាបបំផុត និងបានទៅដល់គ្រប់ទិសទីទូទាំងប្រទេស ហើយនិងចំណេញបានច្រើននោះ។ សូមទំនាក់ទំនងមកកាន់ការិយាល័យអ្នកនាំសារ ឬអាចទូរស័ព្ទ : ០៩២ ៧៣៧ ២៥៥។